មាតិកា

I_ខុទ្ទកាល័យព្រះមហាក្សត្រ

១_ព្រះរាជក្រម

២៤-៦-២០០៧ -ព្រះរាជក្រម នស/រកម/០៦០៧/០១៣ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពី ស្តង់ដារកម្ពុជា ៤៦៦០

២_ព្រះរាជក្រឹត្យ

០៧-៦-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៦០៧/២២៣ ស្តីពីការតែងតាំង ឯកឧត្តមចំនួន ០២ រូប ជាទីប្រឹក្សាផ្ទាល់អគ្គលេខាធិការព្រឹទ្ធសភា សំរាប់នីតិកាលទី ២ ៤៦៩១

១០-៦-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៦០៧/២៣២ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ហ្សានីញេ រ៉ូសេ្ស ល្វី ស្សូសែហ្វ** (ZANNIER ROGER LOUIS JOSEPH) ជនជាតិបារាំង សញ្ជាតិបារាំង កើតនៅសាំងសាម៉ុងដឺ ប្រទេសបារាំង ៤៦៩២

១៧-៦-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៦០៧/២៤០ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ពឹង ពីងគួង** (PENG BING GUANG) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តហ៊ុជៀន ប្រទេសចិន ៤៦៩៣

២៤-៦-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៦០៧/២៥០ ស្តីពីការកំណត់ជាក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិវរមន្ត្រី តាមលក្ខន្តិកៈដោយឡែក នូវមន្ត្រីរាជការស៊ីវិលរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ៤៦៩៤

II_រាជរដ្ឋាភិបាល

អនុក្រឹត្យ

០៣-៧-២០០៧ -អនុក្រឹត្យលេខ៦៦ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៤៧០៣

២៧-៦-២០០៧ -អនុក្រឹត្យលេខ ៤៨៤ អនក្រ.តត ស្តីពីការតែងតាំងអគ្គនាយក រដ្ឋាករទឹកស្វយ័ត សៀមរាប ៤៧០៥

២៧-៦-២០០៧ -អនុក្រឹត្យលេខ ៤៨៥ អនក្រ.តត ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលនៃ រដ្ឋាករទឹកស្វយ័ត សៀមរាប អាណត្តិ ទី ១ ៤៧០៧

២៨-៦-២០០៧ -អនុក្រឹត្យលេខ ៤៨៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៤៧០៩

២៩-៦-២០០៧ -អនុក្រឹត្យលេខ ៤៨៧ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៤៧១០

២៩-៦-២០០៧ -អនុក្រឹត្យលេខ ៤៨៨ អនក្រ.តត ស្ដីពីការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ ៤៧១១
២៩-៦-២០០៧ -អនុក្រឹត្យលេខ ៤៨៩ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៤៧១២
០២-៧-២០០៧ -អនុក្រឹត្យលេខ ៤៩០ អនក្រ.តត ស្ដីពីការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការពីឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ៤៧១៣
០២-៧-២០០៧ -អនុក្រឹត្យលេខ ៤៩១ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៤៧១៤
០២-៧-២០០៧ -អនុក្រឹត្យលេខ ៤៩២ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៤៧១៧
០២-៧-២០០៧ -អនុក្រឹត្យលេខ ៤៩៣ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៤៧១៨
០២-៧-២០០៧ -អនុក្រឹត្យលេខ ៤៩៤ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៤៧១៩
០២-៧-២០០៧ -អនុក្រឹត្យលេខ ៤៩៥ អនក្រ.តត ស្ដីពីការតម្លើងថ្នាក់មន្ត្រីរាជការក្នុងឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ៤៧២០
០៣-៧-២០០៧ -អនុក្រឹត្យលេខ ៤៩៦ អនក្រ.តត ស្ដីពីការតែងតាំងមុខងារ នាយទាហាន ៤៧២២
០៣-៧-២០០៧ -អនុក្រឹត្យលេខ ៤៩៧ អនក្រ.តត ស្ដីពីការផ្ទេរ និងប្រគល់ឋានន្តរស័ក្តិ ៤៧២៣

III.ការងារបណ្ដាក្រសួង

១.ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

១២-៦-២០០៧ -ប្រកាសលេខ ៤៦៥ សហវ ស្ដីពីការដាក់ឱ្យប្រើតារាងពន្ធគយកម្ពុជា ឆ្នាំ ២០០៧ ៤៧២៤

២.ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៨-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦៣១ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិល អេច ឡូជីស្ទីក** ៤៧៧១
០៨-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦៣៣ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឈុន ហេង ឡុង អ៊ីមផត អិចផត** ៤៧៧៣
០៩-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦៣៦ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឈៀន ឆាំង ខមភេនី លីមីធីត** ៤៧៧៥
០៩-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦៣៧ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លីហ្វ៊ីយ៉ូម ខមភេនី លីមីធីត** ៤៧៧៧

០៩-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦៣៨ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេ.ឈីសា ហ្វូលឌីង គ្រុប ខូ អិលធីឌី** ៤៧៧៩

០៩-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦៣៩ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឈាម ឆាក់ ខមភេនី លីមីធីត** ៤៧៨១

០៩-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦៤៤ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ អិម ឌី អេច អ៊ីមផត អិចផត** ៤៧៨៣

០៩-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦៤៥ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ អ៊ី ឌី ស៊ី ខូ អិលធីឌី** ៤៧៨៥

០៩-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦៤៦ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ព្រះខំន អ៊ិនវេសមេន (ខេមបូឌា)** ៤៧៨៧

០៩-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦៨០ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធី វី ឌី ខូ អិលធីឌី** ៤៧៨៩

០៩-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦៨១ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វីស គ្លូប៊ល អ៊ិន វេសមេន (ខេមបូឌា)** ៤៧៩១

០៩-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦៨៤ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេ អេច (ខេមបូឌា) ខូ អិលធីឌី** ៤៧៩៣

១២-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦៩១ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឆយ** ៤៧៩៥

១២-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦៩២ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេដ អង្វ អ៊ីមផត អិចផត** ៤៧៩៧

១២-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦៩៣ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឈិន ភាមប៊ីស ត្រេឌីង** ៤៧៩៩

ព្រះរាជក្រម

នស/រកម/០៦០៧/០១៣

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានទ្រង់យល់ សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាសឱ្យប្រើ

ច្បាប់ស្ដីពី ស្ដង់ដារកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៣ នីតិកាលទី២ រួចហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ច្បាប់

ស្តីពី

ស្តង់ដារកម្ពុជា

ROYAUME DU CAMBODGE * LE MINISTERE DU PALAIS ROYAL *

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះ មានវិសាលភាពលើរាល់សកម្មភាព ដែលទាក់ទងនឹងស្តង់ដារូបនីយកម្ម ការធានាគុណភាពនិងសកម្មភាពពាក់ព័ន្ធទាំងឡាយ ដែលមានក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២.-

ច្បាប់នេះមានគោលបំណង :

ក-ធ្វើឱ្យកាន់តែប្រសើរឡើងនូវគុណភាពផលិតផល សេវាកម្ម និងការគ្រប់គ្រង ។

ខ-បង្កើនប្រសិទ្ធភាពផលិតកម្មឱ្យកាន់តែប្រសើរឡើង និងងាយស្រួល ។

គ-ធានាឱ្យការធ្វើពាណិជ្ជកម្ម មានលក្ខណៈត្រឹមត្រូវ និងងាយស្រួល ។

ឃ-បង្កឱ្យការប្រើប្រាស់ផលិតផលមានលក្ខណៈងាយស្រួល ។

ង-បង្កើនការការពារអ្នកប្រើប្រាស់ និងលើកកម្ពស់សុខុមាលភាពសាធារណៈ ។

មាត្រា ៣.-

លើកលែងតែមានសេចក្តីចែងផ្សេងពីនេះ បណ្តាពាក្យដែលប្រើប្រាស់ក្នុងច្បាប់នេះ មានអត្ថន័យនិងការបកស្រាយដូចខាងក្រោម :

- **អង្គភាពវាយតម្លៃទទួលស្គាល់** សំដៅដល់អង្គភាពដែលអនុវត្តនិងគ្រប់គ្រងប្រព័ន្ធវាយតម្លៃទទួលស្គាល់ និងផ្តល់នូវវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ។

- **ការវាយតម្លៃទទួលស្គាល់** សំដៅដល់នីតិវិធីមួយដែលប្រតិបត្តិដោយអង្គភាពមានសមត្ថកិច្ច ដើម្បីផ្តល់ការទទួលស្គាល់ជាផ្លូវការថា អង្គភាពមួយ ឬបុគ្គលណាមួយមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តតាមភារកិច្ចកំណត់ ។

- **ស្តង់ដារ** មានន័យថា ជាឯកសារដែលត្រូវបានបង្កើតឡើងដោយការព្រមព្រៀងគ្នា និងបានអនុម័តដោយស្ថាប័នមានសមត្ថកិច្ច ដែលមានលក្ខណៈជាក្បួន ជាគោល-ការណ៍ណែនាំ ឬ ជាចរិតលក្ខណៈសម្រាប់សកម្មភាព ឬ លទ្ធផល ដើម្បីទុកសម្រាប់ប្រើប្រាស់ជាទូទៅនិងជាបន្តបន្ទាប់ សំដៅធានាសម្រេចឱ្យបានដល់ចំណុចប្រសើរបំផុតនៃបរិបទមួយ ។

- **ស្តង់ដារូបនីយកម្ម** មានន័យថា ជាសកម្មភាពនៃការបង្កើតនូវបញ្ញត្តិទាំងឡាយ ដែលទាក់ទិនដល់បញ្ហាជាក់ស្តែង ឬ បញ្ហាសំខាន់ៗ ដើម្បីទុកសម្រាប់ការប្រើប្រាស់ជារួម និងប្រើប្រាស់តទៅ សំដៅធានាឱ្យ បានដល់ចំណុចប្រសើរបំផុតនៃបរិបទមួយ ។ សកម្មភាពខាងលើនេះមានជាអាទិ៍ ដំណើរការនៃការបង្កើត ការចេញ និងការអនុវត្តស្តង់ដារ ។

- **ស្តង់ដារកម្ពុជា** សំដៅដល់ ស្តង់ដារដែលអនុម័តដោយក្រុមប្រឹក្សាស្តង់ដារជាតិ និងប្រកាសឱ្យប្រើដោយរដ្ឋមន្ត្រី ។

- **ស្តង់ដារបញ្ជា** សំដៅដល់ស្តង់ដារដែលត្រូវអនុវត្តតាមជាដាច់ខាត ។

- **សញ្ញាស្តង់ដារ** សំដៅដល់សញ្ញាបញ្ជាក់ផលិតផល ឬ សញ្ញាបញ្ជាក់ប្រព័ន្ធ ។

- **សញ្ញាបញ្ជាក់ផលិតផល** សំដៅដល់សញ្ញាដែលបញ្ជាក់ពីភាពអនុលោមនៃផលិតផលមួយ តាមការតម្រូវនៃស្តង់ដារផលិតផលមួយ មានសញ្ញាបញ្ជាក់គុណភាព សុវត្ថិភាព ចុះបញ្ជីផលិតផល ។ល។

- **សញ្ញាបញ្ជាក់ប្រព័ន្ធ** សំដៅដល់សញ្ញាដែលបញ្ជាក់ពីភាពអនុលោមនៃប្រព័ន្ធមួយទៅតាមការតម្រូវនៃស្តង់ដារជាតិ ឬ ស្តង់ដារអន្តរជាតិមួយដែលបានទទួលស្គាល់ ក្នុងនោះមានសញ្ញាបញ្ជាក់ប្រព័ន្ធគ្រប់គ្រងគុណភាព ប្រព័ន្ធគ្រប់គ្រងបរិស្ថាន ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ ។ល។

- **អាជ្ញាប័ណ្ណ** គឺជាលិខិតអនុញ្ញាត ដែលវិទ្យាស្ថានបានចេញឱ្យតាមការស្នើសុំ ដើម្បីប្រើសញ្ញាស្តង់ដារ ។

- **ការបញ្ជាក់** សំដៅដល់ នីតិវិធីមួយដែលក្នុងនោះ តតិយជនម្នាក់ផ្តល់ការធានាជាលាយលក្ខណ៍អក្សរថាទំនិញ ដំណើរការ ការអនុវត្ត ឬ សេវាកម្មសមស្របទៅតាមការតម្រូវដែលបានកំណត់ ។ (តតិយជន សំដៅដល់អង្គភាព ឬបុគ្គលណាមួយដែលទទួលស្គាល់ថាមានភាពឯករាជ្យចំពោះអ្នកផ្គត់ផ្គង់និងអ្នកទិញ) ។

- **ការវាយតម្លៃភាពអនុលោម** សំដៅដល់សកម្មភាពណាមួយដែលពាក់ព័ន្ធដល់ការកំណត់ដោយផ្ទាល់ ឬ ដោយប្រយោលថា ការតម្រូវដែលពាក់ព័ន្ធទាំងឡាយត្រូវបាន

ការធានាគុណភាព សំដៅដល់សកម្មភាពដែលបានគ្រោងទុក និងបានរៀបចំ

ជាប្រព័ន្ធគុណភាព ដើម្បីផ្តល់នូវទំនុកចិត្តគ្រប់គ្រាន់ដែលផលិតផល ឬសេវាកម្មនឹងបំពេញតាមការតម្រូវសម្រាប់គុណភាព ។

- **ទំនិញ** សំដៅដល់របស់របរ ផលិតផល ឬ ជាវត្ថុអ្វីមួយ ដែលជាកម្មវត្ថុក្នុងការធ្វើពាណិជ្ជកម្ម ។

- **ក្រុមប្រឹក្សា** សំដៅដល់ក្រុមប្រឹក្សាស្តង់ដារជាតិ ។

- **វិទ្យាស្ថាន** សំដៅដល់វិទ្យាស្ថានស្តង់ដារកម្ពុជា ។

- **ប្រធាន** សំដៅដល់ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា ។

- **អធិការ** សំដៅដល់បុគ្គលណាមួយដែលប្រធានបានតែងតាំងឡើង ដើម្បីអនុវត្តច្បាប់នេះ ។

- **រដ្ឋមន្ត្រី** សំដៅដល់រដ្ឋមន្ត្រីដែលទទួលបន្ទុកវិស័យឧស្សាហកម្ម និងត្រួតពិនិត្យមើលលើស្តង់ដារូបនីយកម្ម និងការធានាគុណភាព ។

ជំពូកទី ២

វិទ្យាស្ថានស្តង់ដារកម្ពុជា

មាត្រា ៤.-

ត្រូវបានបង្កើតអង្គភាពស្តង់ដារជាតិមួយមានឈ្មោះថា**វិទ្យាស្ថានស្តង់ដារកម្ពុជា** ដែលស្ថិតនៅក្រោមក្រសួងទទួលបន្ទុកវិស័យឧស្សាហកម្ម ។ វិទ្យាស្ថានមានត្រាសម្គាល់របស់ខ្លួនមួយដោយឡែក ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់វិទ្យាស្ថាន ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥.-

មុខងារនិងភារកិច្ចសំខាន់ៗរបស់វិទ្យាស្ថានស្តង់ដារកម្ពុជាមានជាអាទិ៍ដូចខាងក្រោម :

ក-រៀបចំស្តង់ដារជាតិសម្រាប់ផលិតផល ទំនិញ សម្ភារៈ សេវា ការអនុវត្ត និងការប្រតិបត្តិ និងផ្សព្វផ្សាយ ដើម្បីឱ្យមានការទទួលយកជាទូទៅនៃស្តង់ដារទាំងនោះ ។

ខ-អនុវត្តការវាយតម្លៃភាពអនុលោមស្របតាមបញ្ញត្តិ ដែលមានចែងក្នុងច្បាប់

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

គ-បង្កើត និងថែទាំមន្ទីរពិសោធន៍ បណ្ណាល័យ មធ្យោបាយ និងឧបករណ៍ផ្សេងទៀត ដើម្បីលើកកម្ពស់ស្តង់ដារូបនីយកម្មនិងគុណភាព ។

ឃ-បញ្ជាក់ភាពអនុលោមតាមស្តង់ដារសម្រាប់ផលិតផល ទំនិញ សារធាតុ សម្ភារៈ និងបរិក្ខារសម្រាប់ការប្រើប្រាស់ក្នុងស្រុក ឬសម្រាប់ការនាំចេញតាមសំណើរបស់អ្នកស្នើសុំ ។

ង-បញ្ជាក់ភាពអនុលោមតាមស្តង់ដារសុវត្ថិភាព សម្រាប់ផលិតផល ទំនិញ សារធាតុ សម្ភារៈ និងបរិក្ខារ សម្រាប់ការប្រើប្រាស់ក្នុងស្រុក ឬ សម្រាប់ការនាំចេញ តាមសំណើរបស់អ្នកស្នើសុំ ។

ច-បញ្ជាក់ភាពអនុលោមតាមស្តង់ដារសម្រាប់ប្រព័ន្ធគ្រប់គ្រងផលិតកម្ម និងសេវាតាមសំណើរបស់អ្នកស្នើសុំ ។

ឆ-ព្យួរទុក ដកហូត និងលុបចោលអាជ្ញាប័ណ្ណបញ្ជាក់ផលិតផល ឬវិញ្ញាបនបត្របញ្ជាក់ភាពអនុលោម ឬវិញ្ញាបនបត្របញ្ជាក់ឬចុះបញ្ជីប្រព័ន្ធ ឬវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬ ចុះបញ្ជី ។

ជ-ស្រាវជ្រាវអំពីស្តង់ដារូបនីយកម្ម ។

ឈ-ផ្តល់សេវាអប់រំ បណ្តុះបណ្តាល និងការពិគ្រោះយោបល់ ដើម្បីផ្សព្វផ្សាយស្តង់ដារូបនីយកម្ម និងគុណភាព ។

ញ-ទទួលស្គាល់មន្ទីរពិសោធន៍ មធ្យោបាយ និងឧបករណ៍ផ្សេងទៀតរបស់អង្គភាពក្នុងស្រុក និងបរទេសសម្រាប់គោលបំណងរបស់វិទ្យាស្ថាន ។

ដ-ផ្តល់កិច្ចសហប្រតិបត្តិការជាមួយបុគ្គល អង្គការអន្តរជាតិ ឬសមាគមក្រៅប្រទេស ដែលមានកម្មវត្ថុនិងគោលបំណងដូចគ្នា ។

ឋ-ជំរុញនិងលើកទឹកចិត្តការអនុវត្តស្តង់ដារ និងស្តង់ដារូបនីយកម្មឱ្យទៅជាមធ្យោបាយមួយ សម្រាប់ការរីកចំរើននៃសេដ្ឋកិច្ចជាតិ សម្រាប់សុខភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ ។

ឌ-សហការជាមួយអាជ្ញាធរមូលដ្ឋាន ផ្នែកឧស្សាហកម្ម ពាណិជ្ជកម្ម និងអង្គ-ការនានា ដើម្បីធានាទូវការអនុវត្តស្តង់ដារ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា ៦.-

វិទ្យាស្ថានស្តង់ដារកម្ពុជា ត្រូវដឹកនាំគ្រប់គ្រងដោយប្រធានមួយរូប មានឋានៈស្មើអគ្គនាយក ដែលមានលក្ខណសម្បត្តិសមស្រប មានសញ្ញាប័ត្រកម្រិតឧត្តមសិក្សាខាងផ្នែកវិទ្យាសាស្ត្របច្ចេកទេសព្រមទាំងមានបទពិសោធន៍យ៉ាងតិចប្រាំឆ្នាំក្នុងការងារស្តង់ដារូបនីយកម្ម ។

ប្រធានអាចមានអនុប្រធានមួយរូប ឬ ច្រើនរូបតាមការចាំបាច់ ។

មាត្រា ៧.-

ប្រធានអាចចាត់តាំងបុគ្គលិករបស់វិទ្យាស្ថាន ឬបុគ្គលផ្សេងទៀត ដែលប្រធានយល់ថា មានលក្ខណសម្បត្តិសមស្របឱ្យធ្វើជាអធិការនិងត្រូវចេញលិខិតបញ្ជាក់ដល់អធិការដើម្បីជាការបញ្ជាក់ថា អធិការរូបនោះ ត្រូវចាត់តាំងឱ្យបំពេញការងារស្របតាមគោលបំណងនៃច្បាប់នេះ ។

មាត្រា ៨.-

បែបបទនៃការធ្វើអធិការកិច្ច ត្រូវបានកំណត់ដូចតទៅ :

១-តាមការណែនាំជាលាយលក្ខណ៍អក្សររបស់ប្រធាន អធិការអាចចូលក្នុងបរិវេណ ទីតាំង ដោយបង្ហាញលិខិតអនុញ្ញាតដល់អ្នកកាន់កាប់ដើម្បី :

ក-ពិនិត្យនិងយកគំរូផលិតផលឬទំនិញ ឬ សម្ភារៈ ឬ សារធាតុ ដែលបានប្រើប្រាស់ ឬ ដែលសង្ស័យថានឹងយកមកប្រើប្រាស់ក្នុងកម្មន្តសាល

ខ-បើកកញ្ចប់ ឬ កុងតឺន័រណាដែលមានផ្ទុក ឬ ដែលសង្ស័យថាមានផ្ទុកផលិតផល ឬ ទំនិញ ឬ សម្ភារៈ ឬ សារធាតុ ចំពោះផលិតផលឬទំនិញ :

-ដែលស្នើសុំអាជ្ញាប័ណ្ណ ឬ

-ដែលមានប្រើសញ្ញាស្តង់ដារដោយគ្មានអាជ្ញាប័ណ្ណ ឬ

-ដែលមានអាជ្ញាប័ណ្ណហើយ តែត្រូវសង្ស័យថាបានផលិត ឬ បានកែច្នៃក្នុងផលិតកម្មដែលមិនអនុលោមទៅតាមស្តង់ដារពាក់ព័ន្ធ ឬ

-ដែលតម្រូវឱ្យអនុលោមតាមស្តង់ដារបញ្ជា ។

២-យោងតាមវាក្យខណ្ឌទី ១ អធិការអាច :

ក-តម្រូវឱ្យ បុគ្គលដែលគ្រប់គ្រងកម្មន្តសាល បង្ហាញសៀវភៅ លិខិតជូនដំណឹង កំណត់ត្រា បញ្ជី ឬ ឯកសារផ្សេងទៀតដែលពាក់ព័ន្ធ

ខ-ពិនិត្យកត់ត្រា ឬ ថតចម្លងឯកសារផ្សេងៗ ដែលទាក់ទិនទៅនឹងកម្មន្តសាល ឬ ផលិតផល ឬ ទំនិញដែលបានចេញលិខិតអនុញ្ញាតឱ្យ ដោយតម្រូវឱ្យ បុគ្គលគ្រប់គ្រងពន្យល់ និងរឹបអូសយកឯកសារទាំងនោះក្នុងករណីមានកំហុសឆ្គង

គ-សាកសួរព័ត៌មានពីគ្រប់បុគ្គលដែលយល់ឃើញថាចាំបាច់

ឃ-តម្រូវឱ្យ បុគ្គលពាក់ព័ន្ធចូលមកបង្ហាញខ្លួននៅចំពោះមុខតាមពេលវេលានិងទីកន្លែងកំណត់ ដើម្បីផ្តល់ព័ត៌មានបន្ថែម ។

៣-អធិការដែលចុះទៅបំពេញភារកិច្ចក្នុងបរិវេណទីតាំង ត្រូវអនុវត្តតាមនីតិវិធីរដ្ឋបាលទូទៅស្តីពីការត្រួតពិនិត្យ ។

៤-អធិការត្រូវធ្វើកំណត់ហេតុនិងរបាយការណ៍ស្តីពីការចុះត្រួតពិនិត្យនេះ ។

៥-បុគ្គលគ្រប់គ្រងក្នុងបរិវេណទីតាំង ត្រូវបង្កលក្ខណៈងាយស្រួលដល់អធិការគ្រប់ពេលក្នុងការចូលបំពេញភារកិច្ចក្នុងបរិវេណទីតាំងរបស់ខ្លួន ។

មាត្រា ៩.-

មុនពេលចុះទៅបំពេញភារកិច្ច ប្រធាននិងបុគ្គលិកវិទ្យាស្ថាន ត្រូវចុះហត្ថលេខាលើប្រតិវេទន៍មួយ ដែលមានខសន្យារក្សាការសម្ងាត់ ក្នុងពេលចុះបំពេញភារកិច្ច ឬ អនុវត្តមុខងាររបស់ខ្លួន ថានឹងមិនលាតត្រដាងព័ត៌មានចេញទៅខាងក្រៅឡើយ លើកលែងតែ :

-មានការតម្រូវពីរដ្ឋមន្ត្រី ឬ ពីតុលាការ

-ដើម្បីអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះ ឬ ច្បាប់ផ្សេងទៀត ។

ជំពូកទី ៣
ក្រុមប្រឹក្សាស្តង់ដារជាតិ

មាត្រា ១០.-

ត្រូវបង្កើតក្រុមប្រឹក្សាមួយមានឈ្មោះថា**ក្រុមប្រឹក្សាស្តង់ដារជាតិ** ដែលមានវិទ្យាស្ថានស្តង់ដារកម្ពុជាទទួលបន្ទុកជាលេខាធិការដ្ឋាន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

៛/៥៤/

មាត្រា ១១.-

ក្រុមប្រឹក្សាស្តង់ដារជាតិមានសមាសភាពដូចខាងក្រោម ៖

-តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	ជាប្រធាន
-ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា	ជាអនុប្រធានអចិន្ត្រៃយ៍
-តំណាងក្រសួងពាណិជ្ជកម្ម	ជាអនុប្រធាន
-តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	ជាអនុប្រធាន
-តំណាងក្រសួងសុខាភិបាល	ជាអនុប្រធាន
-តំណាងក្រសួងបរិស្ថាន	ជាសមាជិក
-តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន	ជាសមាជិក
-តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់	ជាសមាជិក
-តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	ជាសមាជិក
-តំណាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ	ជាសមាជិក
- តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	ជាសមាជិក
-តំណាងក្រសួងទេសចរណ៍	ជាសមាជិក
-តំណាងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា	ជាសមាជិក
-តំណាងរាជបណ្ឌិតសភាកម្ពុជា	ជាសមាជិក
-តំណាងសកលវិទ្យាល័យភូមិន្ទភ្នំពេញ	ជាសមាជិក
-តំណាងសកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល	ជាសមាជិក
-តំណាងសកលវិទ្យាល័យភូមិន្ទកសិកម្ម	ជាសមាជិក
-តំណាងសភាពាណិជ្ជកម្មកម្ពុជា	ជាសមាជិក
-តំណាងសមាគមអ្នកផលិត	ជាសមាជិក

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

10|32

-តំណាងសមាគមអ្នកប្រើប្រាស់ ជាសមាជិក និង

-តំណាងក្រសួងស្ថាប័នផ្សេងទៀតតាមការចាំបាច់ ជាសមាជិក ។

ឈ្មោះប្រធាន អនុប្រធាន និងសមាជិកក្រុមប្រឹក្សា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យឧស្សាហកម្ម ។

សមាជិកក្រុមប្រឹក្សាមានអាណត្តិបីឆ្នាំ និងអាចត្រូវតែងតាំងជាថ្មី សម្រាប់រយៈពេលបន្តទៀត លើកលែងតែក្នុងករណីលាលែង ឬ បោះបង់ចោលតំណែង ឬ ដកហូតតំណែង ។

សមាជិកនៃក្រុមប្រឹក្សាត្រូវមានលក្ខណសម្បត្តិដូចតទៅ :

-មានសញ្ជាតិខ្មែរ

-មិនដែលមានទោសពីបទឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ

-មានសញ្ញាប័ត្រកម្រិតឧត្តមសិក្សាក្នុងផ្នែកវិទ្យាសាស្ត្រ ឬវិស្វកម្ម និង

-មានបទពិសោធន៍ការងារយ៉ាងតិចប្រាំឆ្នាំ ។

មាត្រា ១២.-

ក្រុមប្រឹក្សាស្តង់ដារជាតិមានភារកិច្ចដូចខាងក្រោម :

ក-សម្រេចយល់ព្រម កែសម្រួល ឬ លុបចោលស្តង់ដារជាតិណាមួយ ។

ខ-សម្រេចយល់ព្រម កែសម្រួល ឬ លុបចោលសញ្ញាស្តង់ដារណាមួយ ។

គ-កំណត់អំពីស្តង់ដារស្ម័គ្រចិត្ត ឬស្តង់ដារបញ្ជា ឬសញ្ញាស្តង់ដារ ។

ឃ-ជូនយោបល់ដល់រដ្ឋមន្ត្រីអំពីអាទិភាព និងគោលនយោបាយនៃស្តង់ដារូប-នីយកម្ម កម្មវិធី ផែនការ គម្រោង និងសកម្មភាពនានា ដើម្បីធានាឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។

ង-ជូនយោបល់ និងលើកអនុសាសន៍ជូនរដ្ឋមន្ត្រី អំពីការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃស្តង់ដារសម្រាប់ផលិតផល ដំណើរការ ការអនុវត្ត ការធ្វើតេស្ត និងសេវាកម្ម និងសម្រេចយល់ព្រមលើកម្មវិធី ផែនការ គម្រោង និងសកម្មភាពនានា សំដៅជំរុញប្រសិទ្ធ-ភាព និងភាពអភិវឌ្ឍឧស្សាហកម្ម និង សម្រាប់ការពារអ្នកប្រើប្រាស់ តាមរយៈសកម្មភាពស្តង់ដារូបនីយកម្ម ។

ច-ដឹកនាំវិទ្យាសាស្ត្រអំពីលក្ខណវិនិច្ឆ័យ និងនីតិវិធីដែលទាក់ទិនដល់ការរៀប

ចំ ការសម្រេចយល់ព្រម ការទទួលយក និងការជ្រើសរើសស្តង់ដារ ។

ឆ-រៀបចំបទបញ្ជាផ្ទៃក្នុង សម្រាប់ការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សា ។

ជ-បំពេញមុខងារដទៃទៀតទៅតាមការកំណត់ ឬ តាមការប្រគល់សិទ្ធិរបស់រដ្ឋមន្ត្រី ។

មាត្រា ១៣.-

សម័យប្រជុំក្រុមប្រឹក្សាអាចប្រព្រឹត្តទៅបាន លុះត្រាតែមានកូរ៉ុមចំនួនលើសពីពាក់កណ្តាលនៃសមាជិកសរុប ។ រាល់សេចក្តីសម្រេចណាមួយរបស់ក្រុមប្រឹក្សា ត្រូវប្រព្រឹត្តទៅដោយមតិភាគច្រើន ពីរភាគបីនៃចំនួនសមាជិកវត្តមានក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា លើកលែងតែការពិនិត្យសម្រេច ឬ ការកែសម្រួលស្តង់ដារជាតិ ដែលត្រូវអនុម័តតាមមតិបីភាគបួននៃចំនួនសមាជិកចូលរួមប្រជុំ ។

មាត្រា ១៤.-

ក្រុមប្រឹក្សាអាចបង្កើតគណៈកម្មការមួយចំនួនបាន ដើម្បីជួយបំពេញមុខងារ និងភារកិច្ច ឬ សម្រាប់គោលបំណងផ្សេងទៀត ដែលកើតឡើង ឬ ដែលទាក់ទិនដល់មុខងារ និងភារកិច្ចរបស់ខ្លួន ។ ក្រុមប្រឹក្សាអាចធ្វើការកែសម្រួល ឬ លុបចោលសេចក្តីសម្រេចណាមួយដែលគណៈកម្មការបានអនុម័តរួចហើយ ។

ជំពូកទី ៤

ស្តង់ដារកម្ពុជា

មាត្រា ១៥.-

រដ្ឋមន្ត្រីត្រូវចេញសេចក្តីប្រកាសចំពោះស្តង់ដារណាមួយថាជាស្តង់ដារកម្ពុជា ដែលក្រុមប្រឹក្សាបានសម្រេចស្របតាមគោលបំណងនៃច្បាប់នេះ ដោយចុះផ្សាយក្នុងរាជកិច្ច ។

រដ្ឋមន្ត្រីអាចកំណត់កាលបរិច្ឆេទចូលជាធរមាន អាចធ្វើការកែសម្រួល និងដកហូតស្តង់ដារទៅតាមការស្នើរបស់ក្រុមប្រឹក្សា ។

13/32

រដ្ឋមន្ត្រីត្រូវបញ្ជាក់ពីមូលហេតុ ដែលនឹងត្រូវចុះផ្សាយក្នុងរាជកិច្ចអំពីការកំណត់កាលបរិច្ឆេទចូលជាធរមាននៃការកែសម្រួល និងការដកហូតស្តង់ដារ ។

មាត្រា ១៦.-

ក្នុងគោលបំណងធានាឱ្យមានសុវត្ថិភាពពិតប្រាកដ ដើម្បីបង្ការភាពមហន្តរាយដែលប៉ះពាល់ជាសាធារណៈ ឬ ប៉ះពាល់ដល់វិស័យឧស្សាហកម្ម ឬ សេដ្ឋកិច្ចជាតិ ប្រភេទនៃផលិតផល ឬ ប្រព័ន្ធណាមួយ ត្រូវអនុលោមទៅតាមស្តង់ដារណាមួយជាកំណត់ ហើយស្តង់ដារនោះត្រូវកំណត់ជាស្តង់ដារបញ្ជា តាមការស្នើរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងតាមការសម្រេចរបស់ក្រុមប្រឹក្សា ។

ការកំណត់ស្តង់ដារបញ្ជាត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រី ហើយកាលបរិច្ឆេទចូលជាធរមានមិនត្រូវឱ្យតិចជាងហុកសិប(៦០)ថ្ងៃ ចាប់ពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាស ។

មាត្រា ១៧.-

មុនពេលរដ្ឋមន្ត្រីចេញប្រកាស ដូចមានចែងក្នុងមាត្រា ១៥និងមាត្រា ១៦ នៃច្បាប់នេះ :

ក-វិទ្យាស្ថានត្រូវផ្សព្វផ្សាយជាសាធារណៈ និងយ៉ាងហោចណាស់នៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានណាមួយប្រចាំថ្ងៃជាភាសាខ្មែរ ក្នុងរយៈពេលមួយមិនតិចជាងប្រាំពីរ(៧)ថ្ងៃ នូវសេចក្តីប្រកាសមួយបញ្ជាក់អំពីគោលបំណង និងខ្លឹមសារសង្ខេបនៃស្តង់ដារណាមួយ ។ បុគ្គលណាមានបំណងតវ៉ា ត្រូវធ្វើការតវ៉ាជាលាយលក្ខណ៍អក្សរទៅវិទ្យាស្ថាន ក្នុងរយៈពេលសាមសិប (៣០)ថ្ងៃ គិតចាប់ពីថ្ងៃចុះផ្សាយព័ត៌មាននោះ ។

ខ-ប្រសិនបើពុំមានការតវ៉ាទេ វិទ្យាស្ថានត្រូវធ្វើរបាយការណ៍ទៅក្រុមប្រឹក្សាហើយក្នុងករណីនេះ ក្រុមប្រឹក្សាត្រូវដំណើរការបន្តទៀត ។

គ-ក្នុងករណីដែលមានការតវ៉ា វិទ្យាស្ថានត្រូវបញ្ជូនពាក្យតវ៉ាទៅក្រុមប្រឹក្សា ។

ឃ-វិទ្យាស្ថានត្រូវបិទសេចក្តីជូនដំណឹងមួយនៅក្នុងវិទ្យាស្ថាន ដោយបញ្ជាក់ពី

កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងដែលត្រូវធ្វើការដោះស្រាយលើពាក្យតវ៉ា ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកតវ៉ា យ៉ាងហោចណាស់ប្រាំពីរ (៧)ថ្ងៃ មុនកាលបរិច្ឆេទធ្វើការដោះស្រាយ ។

ង-ក្រុមប្រឹក្សាត្រូវផ្តល់ឱកាសដល់ជនទាំងឡាយណាដែលមានការចាប់អារម្មណ៍ចូលរួមនិងផ្តល់មតិនៅក្នុងការដោះស្រាយនោះ ។

ច-ប្រសិនបើអ្នកតវ៉ាមិនបានមកចូលរួមក្នុងការដោះស្រាយតាមពេលវេលាដែលបានកំណត់ទេ ក្រុមប្រឹក្សាមានសិទ្ធិដំណើរការដូចដែលខ្លួនគិតថាសមស្រប ។

ឆ-នៅពេលដែលក្រុមប្រឹក្សាធ្វើសេចក្តីសម្រេចរួចហើយ វិទ្យាស្ថានត្រូវបិទផ្សាយសេចក្តីសម្រេចថតចម្លងនៅក្នុងវិទ្យាស្ថាន ហើយត្រូវផ្ញើសេចក្តីសម្រេចថតចម្លងមួយច្បាប់ទៅអ្នកតវ៉ា ។

មាត្រា ១៨.-

បុគ្គលណាដែលពាក់ព័ន្ធនឹងការសម្រេចរបស់ក្រុមប្រឹក្សាស្របតាមមាត្រា ១៧ ចំណុច ឆ នៃច្បាប់នេះ មានសិទ្ធិតវ៉ាទៅរដ្ឋមន្ត្រី ដើម្បីជំទាស់ទៅនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ គិតចាប់ពីថ្ងៃបិទផ្សាយសេចក្តីសម្រេចថតចម្លងនៅក្នុងវិទ្យាស្ថាន ។ រដ្ឋមន្ត្រីត្រូវបញ្ជូនលិខិតតវ៉ាទៅក្រុមប្រឹក្សា ដោយភ្ជាប់ជាមួយនូវអនុសាសន៍របស់ខ្លួន ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាពេលនេះ គឺជាសេចក្តីសម្រេចចុងក្រោយ ។

រដ្ឋមន្ត្រីត្រូវជូនដំណឹងទៅអ្នកតវ៉ាអំពីសេចក្តីសម្រេចចុងក្រោយនេះ ។

មាត្រា ១៩.-

ក្រសួងស្ថាប័ន ឬ អង្គការពាក់ព័ន្ធណាមួយ អាចធ្វើសំណើទៅក្រុមប្រឹក្សា ដើម្បីសុំបង្កើតស្តង់ដារកម្ពុជាជាក់លាក់មួយ ។ ប្រសិនបើក្រុមប្រឹក្សាយល់ថា មិនជាការចាំបាច់ទេនោះ ក្រុមប្រឹក្សាត្រូវបញ្ជាក់ពីមូលហេតុ និងជូនដំណឹងទៅក្រសួង ស្ថាប័ន ឬ អង្គការពាក់ព័ន្ធនោះវិញ ។

ជំពូកទី ៥

សញ្ញាស្តង់ដារកម្ពុជា

មាត្រា ២០.-

យោងតាមមាត្រា ២២ នៃច្បាប់នេះ និងដោយមានការសម្រេចយល់ព្រមពីក្រុមប្រឹក្សា វិទ្យាស្ថានត្រូវផ្សព្វផ្សាយជាសាធារណៈ និងយ៉ាងហោចណាស់ ក៏នៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានណាមួយប្រចាំថ្ងៃជាភាសាខ្មែរ ក្នុងរយៈពេលមួយមិនតិចជាងប្រាំពីរ(៧)ថ្ងៃ បញ្ជាក់អំពីសញ្ញាស្តង់ដារណាមួយ ដែលក្រុមប្រឹក្សាបានសម្រេចយល់ព្រមទាក់ទិនទៅនឹងស្តង់ដារកម្ពុជា សម្រាប់ផលិតផលឬទំនិញ ឬ សម្រាប់ផលិតកម្ម ខ្សែសង្វាក់ផលិតកម្ម ការកែច្នៃ ឬ ប្រព្រឹត្តិកម្មលើផលិតផលឬទំនិញ ឬ សេវាកម្ម ឬ សម្រាប់ប្រព័ន្ធនោះ ។

សេចក្តីជូនដំណឹងក្នុងកថាខណ្ឌ ១ ត្រូវមានព័ត៌មានអំពីស្តង់ដារពាក់ព័ន្ធ ដែលត្រូវបញ្ជាក់ដោយសញ្ញាស្តង់ដារណាមួយនោះ ។ បុគ្គលណាមានបំណងតវ៉ា ត្រូវធ្វើការតវ៉ាជាលាយលក្ខណ៍អក្សរទៅវិទ្យាស្ថានក្នុងរយៈពេលសាមសិប (៣០)ថ្ងៃ គិតចាប់ពីថ្ងៃផ្សាយសេចក្តីជូនដំណឹងនោះ ។

ប្រសិនបើពុំមានការតវ៉ា វិទ្យាស្ថានត្រូវធ្វើរបាយការណ៍ទៅក្រុមប្រឹក្សា ហើយក្នុងករណីនេះ ក្រុមប្រឹក្សាត្រូវដំណើរការបន្តទៀត ។ ក្នុងករណីដែលមានការតវ៉ា វិទ្យាស្ថានត្រូវបញ្ជូនពាក្យតវ៉ាទៅក្រុមប្រឹក្សា ។ ក្រុមប្រឹក្សាត្រូវពិចារណាលើការតវ៉ា និងត្រូវធ្វើការស៊ើបអង្កេត ព្រមទាំងធ្វើការសាកសួរព័ត៌មានផ្សេងៗប្រសិនបើចាំបាច់ ។

ក្នុងករណីចាំបាច់ត្រូវសាកសួរព័ត៌មាន ក្រុមប្រឹក្សាត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ដោយមានការបញ្ជាក់កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងសាកសួរព័ត៌មានទៅឱ្យអ្នកតវ៉ា ។ អ្នកតវ៉ានោះ ត្រូវមកបង្ហាញខ្លួននៅកន្លែងសាកសួរព័ត៌មាន និងមានសិទ្ធិទទួលដំណឹងអំពីការសម្រេចរបស់ក្រុមប្រឹក្សា ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាលើការតវ៉ាខាងលើ ត្រូវប្រគល់ជូនទៅវិទ្យាស្ថាន ដើម្បីផ្សព្វផ្សាយសេចក្តីសម្រេចថតចម្លងនៅក្នុងវិទ្យាស្ថាន ហើយត្រូវធ្វើសេចក្តីសម្រេចថតចម្លងមួយច្បាប់ទៅរាល់បុគ្គលពាក់ព័ន្ធ ។

មាត្រា ២១.-

បុគ្គលដែលពាក់ព័ន្ធដល់ការសម្រេចរបស់ក្រុមប្រឹក្សាស្របតាមកថាខណ្ឌ ៥ នៃមាត្រា ២០ នៃច្បាប់នេះ មានសិទ្ធិតវ៉ាទៅរដ្ឋមន្ត្រីដើម្បីជំទាស់ទៅនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្នុងរយៈពេលដប់ប្រាំ(១៥)ថ្ងៃ គិតចាប់ពីថ្ងៃបិទផ្សាយសេចក្តីសម្រេចថតចម្លងនៅក្នុងវិទ្យាស្ថាន ។ រដ្ឋមន្ត្រីត្រូវបញ្ជូនលិខិតតវ៉ាទៅក្រុមប្រឹក្សា ដោយភ្ជាប់ជាមួយនូវអនុសាសន៍របស់ខ្លួន ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាពេលនេះ គឺជាសេចក្តីសម្រេចចុងក្រោយ ។ រដ្ឋមន្ត្រីត្រូវជូនដំណឹងទៅអ្នកតវ៉ាអំពីការសម្រេចចុងក្រោយនេះ ។

មាត្រា ២២.-

គ្មានសញ្ញាស្តង់ដារណាដែលដូចគ្នាទៅនឹងពាណិជ្ជសញ្ញាណាមួយ ដែលបានចុះបញ្ជីរួចហើយសម្រាប់ផលិតផលឬទំនិញក្រោមច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឬ ដែលស្ទើរតែដូចគ្នាទាំងស្រុង ធ្វើឱ្យច្រឡំគ្នាទៅនឹងពាណិជ្ជសញ្ញានោះ អាចប្រកាសថាជាសញ្ញាស្តង់ដារដែលមានបញ្ជាក់ក្នុងមាត្រា ២០ នៃច្បាប់នេះបានឡើយ ។

គ្មានបុគ្គលណាមួយអាចប្រើប្រាស់ពាណិជ្ជសញ្ញាណា ដែលដូចគ្នានឹងសញ្ញាស្តង់ដារដែលបានប្រកាសស្របតាមមាត្រា ២០ នៃច្បាប់នេះ ឬ ប្រើប្រាស់ពាណិជ្ជសញ្ញាណាដែលស្ទើរតែដូចគ្នាទាំងស្រុងធ្វើឱ្យច្រឡំគ្នាទៅនឹងសញ្ញាស្តង់ដារបានឡើយ ។

មាត្រា ២៣.-

យោងតាមមាត្រា ២០ មាត្រា ២១ និងមាត្រា ២២ នៃច្បាប់នេះ និងតាមសំណើរបស់ក្រុមប្រឹក្សា រដ្ឋមន្ត្រីត្រូវចេញប្រកាសមួយដែលនឹងចុះផ្សាយក្នុងរាជកិច្ចអំពីការដាក់ឱ្យប្រើ ឬ លុបចោល ឬ ធ្វើការកែសម្រួលសញ្ញាស្តង់ដារចំពោះផលិតផលឬទំនិញ ឬ សម្រាប់ផលិតកម្ម ខ្សែសង្វាក់ផលិតកម្ម ការកែច្នៃ ឬ ប្រព្រឹត្តិកម្មលើផលិតផលឬទំនិញ ឬ សេវាកម្ម ឬ សម្រាប់ប្រព័ន្ធគ្រប់គ្រងនោះ ដែលនឹងចូលជាធរមានចាប់ពីថ្ងៃដែលបានបញ្ជាក់ក្នុងប្រកាសនោះ ។ កាលបរិច្ឆេទចូលជាធរមានមិនត្រូវឱ្យលើសពីបី(៣)ខែ គិតចាប់ពីថ្ងៃចេញ

ជំពូកទី ៦

អាជ្ញាប័ណ្ណបញ្ជាក់ផលិតផល

មាត្រា ២៤.-

រាល់ការស្នើសុំអាជ្ញាប័ណ្ណ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរទៅវិទ្យាស្ថាន ។

អាជ្ញាប័ណ្ណអាចចេញឱ្យបាន លុះត្រាតែបានបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

- បានធ្វើអធិការកិច្ច និងការយកគំរូផលិតផលមកធ្វើតេស្ត ដើម្បីបញ្ជាក់ពីភាពអនុលោមតាមស្តង់ដារពាក់ព័ន្ធ
- អ្នកស្នើសុំយល់ព្រមទទួលយកលក្ខខណ្ឌទាំងឡាយ ដែលមានចែងក្នុងអាជ្ញាប័ណ្ណ
- អ្នកស្នើសុំបានបង់កម្រៃស្នើសុំអាជ្ញាប័ណ្ណទៅវិទ្យាស្ថាន តាមការកំណត់ដោយប្រកាសរួមរបស់ក្រសួងទទួលបន្ទុកវិស័យឧស្សាហកម្ម និងក្រសួងទទួលបន្ទុកវិស័យហិរញ្ញវត្ថុ ។

អាជ្ញាប័ណ្ណមានសុពលភាពសម្រាប់រយៈពេលបី(៣)ឆ្នាំ និងអាចត្រូវបន្តជាថ្មីបានសម្រាប់រយៈពេលបី(៣)ឆ្នាំម្តង ប្រសិនបើបានអនុវត្តត្រឹមត្រូវតាមលក្ខខណ្ឌដែលមានចែងក្នុងអាជ្ញាប័ណ្ណនោះ ។

ក្នុងករណីសំណើសុំអាជ្ញាប័ណ្ណត្រូវបដិសេធ វិទ្យាស្ថានត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីពីការបដិសេធទៅបុគ្គលដែលស្នើសុំអាជ្ញាប័ណ្ណនោះយ៉ាងយូរប្រាំពីរ(៧)ថ្ងៃ បន្ទាប់ពីថ្ងៃបញ្ចប់ការវាយតម្លៃភាពអនុលោមតាមស្តង់ដារពាក់ព័ន្ធ ។

មាត្រា ២៥.-

បុគ្គលណាមួយដែលផលិត ឬ កែច្នៃផលិតផលអនុលោមតាមស្តង់ដារដែលបានប្រកាសឱ្យប្រើ និងបានចូលជាធរមានរួចហើយ អាចបិទសញ្ញាស្តង់ដារនៅលើផលិតផលរបស់ខ្លួនបាន បន្ទាប់ពីបានទទួលអាជ្ញាប័ណ្ណពីវិទ្យាស្ថានស្របតាមមាត្រា ២៤ នៃច្បាប់នេះ ។

ក/៣៤

មាត្រា ២៦.–

នៅពេលដែលស្តង់ដារបញ្ញាមួយ ត្រូវប្រកាសដូចមានចែងក្នុងមាត្រា ១៦ នៃច្បាប់នេះ និងក្រោយកាលបរិច្ឆេទចូលជាធរមានដែលបានកំណត់បញ្ជាក់ក្នុងប្រកាសនោះ ការផលិត ឬ ការបន្តផលិតនូវផលិតផលណាមួយ ឬ ការរៀបចំខ្សែសង្វាក់ផលិតកម្មណាមួយ ឬផលិតផលនាំចូលណាមួយ ត្រូវអនុលោមតាមស្តង់ដារបញ្ញានោះ ។

មាត្រា ២៧.–

អ្នកកាន់អាជ្ញាប័ណ្ណត្រូវដាក់តាំងអាជ្ញាប័ណ្ណរបស់ខ្លួននៅកន្លែងដែលអាចមើលឃើញច្បាស់ នៅក្នុងទីតាំងផលិតដែលបានបញ្ជាក់ក្នុងអាជ្ញាប័ណ្ណ ។

ប្រសិនបើអាជ្ញាប័ណ្ណត្រូវបាត់ ឬ ខូចខាតទាំងស្រុងនោះ អ្នកកាន់អាជ្ញាប័ណ្ណត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណទុតិយតាទៅវិទ្យាស្ថានក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ គិតចាប់ពីថ្ងៃដែលដឹងឮជាសាធារណៈ ។

ចំពោះការផ្លាស់ប្តូរទីតាំងផលិតដែលបានបញ្ជាក់ក្នុងអាជ្ញាប័ណ្ណ ឬ បង្កើតសាខា ឬ ពង្រីកផលិតកម្ម អ្នកកាន់អាជ្ញាប័ណ្ណត្រូវសុំអាជ្ញាប័ណ្ណថ្មីពីវិទ្យាស្ថានមុនដំណើរការផលិត ។

សំណុំលិខិតស្នើសុំនិងការចេញអាជ្ញាប័ណ្ណថ្មី ត្រូវអនុលោមតាមគោលការណ៍ និងនីតិវិធីនៃការចេញអាជ្ញាប័ណ្ណ ។

មាត្រា ២៨.–

ក្នុងករណីសំណុំលិខិតស្នើសុំអាជ្ញាប័ណ្ណស្របតាមមាត្រា ២៤ មាត្រា ២៥ មាត្រា ២៦ និងមាត្រា ២៧ នៃច្បាប់នេះត្រូវបានបដិសេធដោយវិទ្យាស្ថាន អ្នកស្នើសុំមានសិទ្ធិតវ៉ាទៅរដ្ឋមន្ត្រីក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ គិតចាប់ពីថ្ងៃជូនព័ត៌មានអំពីការបដិសេធនោះ ។ សេចក្តីសម្រេចរបស់រដ្ឋមន្ត្រី គឺជាសេចក្តីសម្រេចចុងក្រោយ ។

មាត្រា ២៩.–

អាជ្ញាប័ណ្ណមួយត្រូវលុបចោលនៅពេល :

- អ្នកកាន់អាជ្ញាប័ណ្ណបញ្ឈប់ដំណើរការ ឬ
- អ្នកកាន់អាជ្ញាប័ណ្ណស្នើសុំឈប់ប្រើសញ្ញាស្តង់ដារនៅលើផលិតផលរបស់ខ្លួន ឬ

-មានសេចក្តីជូនដំណឹង ឬ ប្រកាសដែលកំណត់អំពីស្តង់ដារថ្មីណាមួយ ឬ ការកែប្រែស្តង់ដារណាមួយ ឬ ការដកហូតស្តង់ដារណាមួយដែលទាក់ទិនទៅនឹងប្រភេទផលិតផលទាំងនោះ ចូលជាធរមាន ។

មាត្រា ៣០.—

នៅពេលបញ្ចប់ដំណើរការរបស់ខ្លួន អ្នកកាន់អាជ្ញាប័ណ្ណត្រូវជូនដំណឹងជាលាយ-លក្ខណ៍អក្សរទៅវិទ្យាស្ថាន ក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ គិតចាប់ពីថ្ងៃដែលបានបញ្ចប់ដំណើរការនោះ ។

ក្នុងករណីមានការកំណត់ស្តង់ដារថ្មីមួយ ឬ មានការកែប្រែស្តង់ដារ អ្នកកាន់អាជ្ញា-ប័ណ្ណដែលមានបំណងអនុលោមតាមស្តង់ដារថ្មី ឬ ស្តង់ដារដែលបានកែប្រែនោះ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណឱ្យបានមុនកាលបរិច្ឆេទចូលជាធរមាននៃស្តង់ដារថ្មី ឬ ស្តង់ដារដែលបានកែប្រែនោះ ។ បន្ទាប់ពីបានដាក់ពាក្យស្នើសុំរួច អ្នកកាន់អាជ្ញាប័ណ្ណអាចបន្តដំណើរការរបស់ខ្លួន នៅក្រោមអាជ្ញាប័ណ្ណនិងស្តង់ដារចាស់ ក្នុងរយៈពេលមួយដែលបានកំណត់ដោយវិទ្យាស្ថាន គឺមិនលើសពីមួយ(១)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃស្តង់ដារថ្មី ឬ ស្តង់ដារដែលបានកែប្រែ ។

មាត្រា ៣១.—

វិទ្យាស្ថានមានសិទ្ធិព្យួរអាជ្ញាប័ណ្ណ ក្នុងរយៈពេលមួយមិនលើសពីបី(៣)ខែ ក្នុងមួយលើក នៅពេលដែលបានរកឃើញថាអ្នកកាន់អាជ្ញាប័ណ្ណរំលោភទៅនឹងបញ្ញត្តិនៃច្បាប់នេះ ឬបទបញ្ជាដែលក្រសួងបានចេញស្របតាមច្បាប់នេះ ឬ លក្ខខណ្ឌដែលបានដាក់ជាបញ្ញត្តិដោយវិទ្យាស្ថាន ឬរកឃើញថាផលិតផលមិនអនុលោមទៅតាមស្តង់ដារដែលបានកំណត់ ។

នៅពេលដែលអាជ្ញាប័ណ្ណ សម្រាប់ផលិតផលណាមួយត្រូវបានព្យួរ អ្នកកាន់អាជ្ញា-ប័ណ្ណមិនត្រូវបញ្ជាក់តាមរូបភាពណាមួយបង្ហាញថាផលិតផលនោះមានអាជ្ញាប័ណ្ណឡើយ ។

ប្រសិនបើបុគ្គលដែលត្រូវព្យួរអាជ្ញាប័ណ្ណ បានកែតម្រូវដោយអនុលោមតាមច្បាប់និងបញ្ញត្តិនានារួចហើយ វិទ្យាស្ថានអាចលុបចោលការព្យួរអាជ្ញាប័ណ្ណ នៅមុនពេលផុតកំណត់នៃរយៈពេលព្យួរ ។

9/32

មាត្រា ៣២.–

វិទ្យាស្ថានមានសិទ្ធិដកហូតអាជ្ញាប័ណ្ណ នៅពេលដែលបានរកឃើញថា អ្នកកាន់អាជ្ញាប័ណ្ណ :

-អនុវត្តខុសធ្ងន់ធ្ងរទៅនឹងការតម្រូវនៃលក្ខខណ្ឌនៃការផ្តល់ និងការប្រើប្រាស់អាជ្ញាប័ណ្ណ ឬ

-មិនបានបំពេញនូវលក្ខខណ្ឌទាំងឡាយ ដែលបានតម្រូវឱ្យធ្វើការកែតម្រូវក្នុងរយៈពេលព្យួរ ឬ

-បានប្រព្រឹត្តកំហុសដូចគ្នាទៅនឹងកំហុសដែលបណ្តាលឱ្យមានការព្យួរអាជ្ញាប័ណ្ណលើកមុន ក្នុងរយៈពេលបី(៣)ឆ្នាំកន្លងមក ឬ

-ខកខានមិនបានបង់កម្រៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ។

មាត្រា ៣៣.–

មុនពេលព្យួរអាជ្ញាប័ណ្ណដូចមានចែងក្នុងមាត្រា ៣១ ឬ ដកហូតអាជ្ញាប័ណ្ណដូចមានចែងក្នុងមាត្រា៣២ នៃច្បាប់នេះ វិទ្យាស្ថានត្រូវជូនដំណឹងពីបំណងរបស់ខ្លួនដល់អ្នកកាន់អាជ្ញាប័ណ្ណឱ្យបានដប់ប្រាំ(១៥)ថ្ងៃមុន និងបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងនោះអំពីមូលហេតុណាមួយដែលនាំឱ្យមានការព្យួរ ឬ ដកហូតអាជ្ញាប័ណ្ណ ។

មាត្រា ៣៤.–

បុគ្គលណាដែលពុំសុខចិត្តចំពោះការព្យួរ ឬ ការដកហូតអាជ្ញាប័ណ្ណដូចដែលបានកំណត់នៅមាត្រា៣១ និងមាត្រា៣២ នៃច្បាប់នេះ អាចធ្វើការតវ៉ាជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រី ក្នុងអំឡុងពេលដប់ប្រាំ(១៥)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលសេចក្តីជូនដំណឹងអំពីការព្យួរ ឬ ការដកហូតនោះ ។ ក្នុងអំឡុងពេលតវ៉ា អ្នកតវ៉ាអាចធ្វើសំណើទៅរដ្ឋមន្ត្រី ដើម្បីសុំពន្យារកាលបរិច្ឆេទចូលជាធរមាននៃបទប្បញ្ញត្តិអំពីការព្យួរ ឬ ការដកហូតអាជ្ញាប័ណ្ណ ។ សេចក្តីសម្រេចរបស់រដ្ឋមន្ត្រី គឺជាការសម្រេចចុងក្រោយ ។

ROYAL SEAL · LE MINISTRE DU PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង

មាត្រា ៣៥.-

បុគ្គលដែលត្រូវដកហូតអាជ្ញាប័ណ្ណសម្រាប់ប្រភេទនៃផលិតផលដោយឡែកណាមួយ មិនអាចស្នើសុំអាជ្ញាប័ណ្ណថ្មីសម្រាប់ផលិតផលនោះបានឡើយ ក្នុងអំឡុងពេលប្រាំមួយ(៦) ខែ គិតចាប់ពីថ្ងៃដែលបានដកហូត ។

មាត្រា ៣៦.-

គ្មានបុគ្គលណាអាចផ្សព្វផ្សាយពាណិជ្ជកម្មលក់ ឬ លក់ផលិតផលណាមួយដែលមានបិទសញ្ញាដោយរំលោភទៅនឹងកថាខណ្ឌ ២ នៃមាត្រា ២២ មាត្រា ២៥ និងមាត្រា ២៦ ឬ ផលិតផល ឬ ទំនិញមានបិទសញ្ញាស្តង់ដារដែលអាជ្ញាប័ណ្ណត្រូវលុបចោល ឬ ព្យួរ ឬ ដកហូតដូចមានចែងក្នុងមាត្រា ២៩ មាត្រា ៣១ និងមាត្រា ៣២ នៃច្បាប់នេះបានឡើយ ។

មាត្រា ៣៧.-

ការលុបចោលអាជ្ញាប័ណ្ណស្របតាមមាត្រា ២៩ និងការដកហូតអាជ្ញាប័ណ្ណស្របតាមមាត្រា ៣២ នៃច្បាប់នេះ ត្រូវផ្សព្វផ្សាយជាសាធារណៈដោយវិទ្យាស្ថាន ។

ជំពូកទី ៧
វិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ

មាត្រា ៣៨.-

អង្គភាពណាដែលមានបំណងចង់បានទទួលវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ អាចធ្វើពាក្យស្នើសុំទៅវិទ្យាស្ថាន ។

អ្នកស្នើសុំត្រូវបង់កម្រៃស្នើសុំវិញ្ញាបនបត្រទៅវិទ្យាស្ថានតាមការកំណត់ដោយប្រកាសរួមរបស់ក្រសួងទទួលបន្ទុកវិស័យឧស្សាហកម្មនិងក្រសួងទទួលបន្ទុកវិស័យហិរញ្ញវត្ថុ ។

ក្រោយពីអនុវត្តតាមនីតិវិធីជាបន្តបន្ទាប់រួចហើយ វិទ្យាស្ថានត្រូវវាយតម្លៃពីភាពអនុលោមនៃប្រព័ន្ធគ្រប់គ្រងរបស់អ្នកស្នើសុំទៅនឹងការតម្រូវនៃស្តង់ដារប្រព័ន្ធពាក់ព័ន្ធ ។

ក្រោយពីមានការសម្រេចយល់ព្រមរបស់វិទ្យាស្ថានលើការស្នើសុំនោះហើយ អង្គភាពដែលបានរៀបរាប់ក្នុងកថាខណ្ឌ ១ ខាងលើនឹងបានទទួលនូវវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធនោះ ដោយត្រូវអនុវត្តតាមលក្ខខណ្ឌដែលបានកំណត់របស់វិទ្យាស្ថាន ។

វិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធមានសុពលភាពសម្រាប់រយៈពេលបី(៣)ឆ្នាំ ប៉ុន្តែប្រសិនបើបានអនុវត្តតាមលក្ខខណ្ឌដែលមានចែងហើយវិញ្ញាបនបត្រនោះអាចត្រូវបន្តជាថ្មីសម្រាប់រយៈពេលបី(៣)ឆ្នាំ ម្តងបាន ។

អង្គភាពដែលដាក់ពាក្យសុំវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ និងអង្គភាពទាំងឡាយដែលបានទទួលវិញ្ញាបនបត្ររួចហើយ ត្រូវដាក់ជូនឯកសារដូចខាងក្រោម :

-ឯកសារទាំងឡាយសម្រាប់ការវាយតម្លៃ ឬ ត្រួតពិនិត្យ និង

-ព័ត៌មានដែលទាក់ទិនដល់ដំណើរការ ឬ ការរៀបចំការដាក់ពាក្យសុំ ឬ ការបានទទួលវិញ្ញាបនបត្រនោះ ។

វិទ្យាស្ថានត្រូវធ្វើបញ្ជីមួយដែលត្រូវកត់ត្រាលម្អិតអំពីវិញ្ញាបនបត្រទាំងឡាយដែលបានផ្តល់ឱ្យរួចហើយ ។ បញ្ជីនេះត្រូវមានតម្កល់សម្រាប់សាធារណជនពិនិត្យនៅវិទ្យាស្ថាន ។

មាត្រា ៣៩.-

អ្នកកាន់វិញ្ញាបនបត្រអាចប្រើប្រាស់វិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ ឬ សញ្ញាបញ្ជាក់ប្រព័ន្ធបាន ដើម្បីកំណត់ថាប្រព័ន្ធគ្រប់គ្រងរបស់អង្គភាពខ្លួនអនុលោមតាមការតម្រូវនៃស្តង់ដារដែលបានកំណត់ នៅក្រោយពេលធ្វើសវនកម្ម និងបន្ទាប់ពីបានទទួលវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធពីវិទ្យាស្ថានស្របតាមមាត្រា ៣៨ នៃច្បាប់នេះ ។

មាត្រា ៤០.-

វិទ្យាស្ថានមានសិទ្ធិព្យួរវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធណាមួយ ក្នុងរយៈពេលមួយមិនលើសពីប្រាំមួយ(៦)ខែ ក្នុងករណីដូចខាងក្រោម :

-ការពិនិត្យអង្កេតបង្ហាញឱ្យឃើញថា មានការអនុវត្តមិនសមស្របតាមការតម្រូវនៃលក្ខខណ្ឌនៃការចេញ និងការប្រើប្រាស់វិញ្ញាបនបត្រ ឬ

-ការប្រើប្រាស់វិញ្ញាបនបត្រ ឬ សញ្ញាបញ្ជាក់ប្រព័ន្ធមិនបានត្រឹមត្រូវ ។

នៅពេលដែលវិញ្ញាបនបត្រសម្រាប់ប្រព័ន្ធគ្រប់គ្រងណាមួយត្រូវព្យួរ អ្នកកាន់វិញ្ញាបនបត្រមិនត្រូវបញ្ជាក់តាមរូបភាពណាមួយបង្ហាញថា ប្រព័ន្ធគ្រប់គ្រងនោះមានវិញ្ញាបនបត្រឡើយ ។

ប្រសិនបើអង្គភាពដែលត្រូវព្យួរវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធបានចាត់និងអនុវត្តវិធានការកែតម្រូវត្រឹមត្រូវរួចហើយ វិទ្យាស្ថានអាចលុបចោលការព្យួរវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធនៅមុនពេលផុតកំណត់នៃរយៈពេលព្យួរ ។

មាត្រា ៤១.-

វិទ្យាស្ថានមានសិទ្ធិដកហូតវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ ក្នុងករណីដូចខាងក្រោម ៖

-ការពិនិត្យអង្កេតបង្ហាញឱ្យឃើញថា ការអនុវត្តមានលក្ខណៈខុសធ្ងន់ធ្ងរទៅនឹងការតម្រូវនៃលក្ខខណ្ឌនៃការផ្តល់ និងការប្រើប្រាស់វិញ្ញាបនបត្រ ឬ

-អ្នកកាន់វិញ្ញាបនបត្ររំលោភទៅនឹងបញ្ញត្តិ ឬ បទបញ្ជាដែលក្រសួងបានចេញ ស្របតាមច្បាប់នេះ ឬ លក្ខខណ្ឌដែលបានដាក់ជាបញ្ញត្តិដោយវិទ្យាស្ថាន ឬ រកឃើញថាប្រព័ន្ធនោះមិនអនុលោមទៅតាមស្តង់ដារដែលបានកំណត់ ឬ

-អ្នកកាន់វិញ្ញាបនបត្រខកខានមិនបានបង់កម្រៃវិញ្ញាបនបត្រប្រចាំឆ្នាំ ឬ

-ការរំលោភទៅនឹងបទប្បញ្ញត្តិណាមួយ ដែលមានចែងក្នុងកិច្ចព្រមព្រៀងវិញ្ញាបនបត្រ ឬ

-មិនបានបំពេញវិធានការកែតម្រូវទាំងឡាយឱ្យបានគ្រប់គ្រាន់ក្នុងអំឡុងពេលនៃការព្យួរ ។

ការដកហូតវិញ្ញាបនបត្រខាងលើ ត្រូវផ្សព្វផ្សាយជាសាធារណៈដោយវិទ្យាស្ថាន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

មាត្រា ៤២.-

មុនពេលព្យួរវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធដូចមានចែងក្នុងមាត្រា ៤០ ឬ ដកហូតវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធដូចមានចែងក្នុងមាត្រា ៤១ នៃច្បាប់នេះ វិទ្យាស្ថានត្រូវជូនដំណឹងពីបំណងរបស់ខ្លួនដល់អ្នកកាន់វិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធឱ្យ បានដប់ប្រាំ(១៥)ថ្ងៃមុន និងបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងនោះ អំពីមូលហេតុណាមួយដែលនាំឱ្យមានការព្យួរ ឬ ដកហូតវិញ្ញាបនបត្រ ។

មាត្រា ៤៣.-

គ្មានបុគ្គលណាមួយអាចផ្សព្វផ្សាយពាណិជ្ជកម្មអំពីការទទួលវិញ្ញាបនបត្របញ្ជាក់ណាមួយដែលមិនអនុលោមទៅតាមលក្ខខណ្ឌនៃមាត្រា ៣៨ ឬ ប្រើសញ្ញាដោយរំលោភទៅនឹងកថាខណ្ឌ ២ នៃមាត្រា ២២ នៃច្បាប់នេះ ឬ អង្គភាពរបស់ខ្លួន ត្រូវបានព្យួរ ឬ ដកហូតវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធដូចមានចែងក្នុងមាត្រា ៤០ និងមាត្រា ៤១ នៃច្បាប់នេះបានឡើយ ។

ជំពូកទី ៨
ការវាយតម្លៃទទួលស្គាល់ និងការចុះបញ្ជី

មាត្រា ៤៤.-

ត្រូវដាក់ពាក្យសុំទៅវិទ្យាស្ថាន ចំពោះបុគ្គល ឬ អង្គភាពណាមួយ ដែលមានបំណងចង់ទទួលយកការវាយតម្លៃទទួលស្គាល់ ឬ ការចុះបញ្ជីដូចជា :

ក-អង្គភាពវាយតម្លៃភាពអនុលោម ។

ខ-មន្ទីរពិសោធន៍ធ្វើតេស្ត ឬ ក្រិតខ្នាត ។

គ-អង្គភាពបណ្តុះបណ្តាលសម្រាប់វាយតម្លៃភាពអនុលោម ។

ឃ-បុគ្គលណាមួយដែលមានលក្ខណសម្បត្តិ ដើម្បីអនុវត្តការវាយតម្លៃភាពអនុលោម និងសវនកម្មទាទា ។

អ្នកស្នើសុំត្រូវបង់កម្រៃស្នើសុំវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ និងវិញ្ញាបនបត្រចុះបញ្ជីទៅវិទ្យាស្ថានតាមការកំណត់ដោយប្រកាសរួមរបស់ក្រសួងទទួលបន្ទុកវិស័យឧស្សាហកម្ម និងក្រសួងទទួលបន្ទុកវិស័យហិរញ្ញវត្ថុ ។

ក្រោយពីអនុវត្តតាមនីតិវិធីជាបន្តបន្ទាប់រួចហើយ វិទ្យាស្ថានត្រូវវាយតម្លៃទទួលស្គាល់ ឬ ទទួលចុះបញ្ជីបុគ្គលដូចមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ទៅនឹងការតម្រូវនៃស្តង់ដារពាក់ព័ន្ធ ។

ក្រោយពីមានការសម្រេចយល់ព្រមរបស់វិទ្យាស្ថានលើការស្នើសុំនោះហើយ បុគ្គលដូចមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះនឹងបានទទួលនូវវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជី ដោយត្រូវអនុវត្តតាមលក្ខខណ្ឌដែលបានកំណត់ដោយវិទ្យាស្ថាន ។

វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជីមានសុពលភាពសម្រាប់រយៈពេលបី(៣)ឆ្នាំ ប៉ុន្តែប្រសិនបើបានអនុវត្តតាមលក្ខខណ្ឌដែលមានចែងហើយ វិញ្ញាបនបត្រនោះអាចត្រូវបន្តជាថ្មីបាន សម្រាប់រយៈពេលបី(៣)ឆ្នាំម្តង ។

បុគ្គល ឬ អង្គភាពដែលដាក់ពាក្យសុំវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជី និងបុគ្គល ឬ អង្គភាពទាំងឡាយដែលបានទទួលវិញ្ញាបនបត្ររួចហើយ ត្រូវដាក់ជូនឯកសារដូចខាងក្រោម:

-ឯកសារទាំងឡាយសម្រាប់ការវាយតម្លៃ ឬ ត្រួតពិនិត្យ និង

-ព័ត៌មានដែលទាក់ទិនដល់ដំណើរការ ឬ ការរៀបចំការដាក់ពាក្យសុំ ឬការបានទទួលវិញ្ញាបនបត្រនោះ ។

វិទ្យាស្ថានត្រូវធ្វើបញ្ជីមួយដែលត្រូវកត់ត្រាលម្អិតអំពីវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជីទាំងឡាយដែលបានផ្តល់ឱ្យរួចហើយ ។ បញ្ជីនេះត្រូវមានតម្កល់សម្រាប់សាធារណជនពិនិត្យនៅវិទ្យាស្ថាន ។

ROYAUME DU CAMBODGE · LE MINISTRE du PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង

មាត្រា ៤៥.-

អ្នកកាន់វិញ្ញាបនបត្រអាចប្រើប្រាស់វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជីបាន ដើម្បីកំណត់ថា បុគ្គល ឬ អង្គភាពរបស់ខ្លួនអនុលោមតាមការតម្រូវនៃស្តង់ដារដែលបានកំណត់ នៅក្រោយពេលធ្វើសវនកម្ម និងបន្ទាប់ពីបានទទួលវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជីពីវិទ្យាស្ថានស្របតាមមាត្រា ៤៤ នៃច្បាប់នេះ ។

មាត្រា ៤៦.-

វិទ្យាស្ថានមានសិទ្ធិព្យួរទុក ឬ ដកហូតវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ និងចុះបញ្ជីក្នុងរយៈពេលមួយមិនលើសពីប្រាំមួយ(៦)ខែ ឬ មានសិទ្ធិដកហូត ឬ លុបចោល ប្រសិនបើពេលវេលា និងលក្ខខណ្ឌដែលបានសរសេរភ្ជាប់ទៅនឹងវិញ្ញាបនបត្រទាំងនេះមិនត្រូវបានគោរពតាម ប៉ុន្តែអ្នកកាន់វិញ្ញាបនបត្រណាដែលត្រូវវិទ្យាស្ថានព្យួរទុក ឬ ដកហូតនូវវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជី អាចដាក់ពាក្យប្តឹងតវ៉ាទៅរដ្ឋមន្ត្រីដើម្បីធ្វើការវិនិច្ឆ័យជាចុងក្រោយ ។

ប្រសិនបើអង្គភាពដែលត្រូវព្យួរវិញ្ញាបនបត្របានចាត់និងអនុវត្តវិធានការកែតម្រូវត្រឹមត្រូវរួចហើយ វិទ្យាស្ថានអាចលុបចោលការព្យួរវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជីនៅមុនពេលផុតកំណត់នៃរយៈពេលព្យួរ ។

នៅពេលដែលវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជីណាមួយត្រូវព្យួរទុក ឬ ដកហូត អ្នកកាន់វិញ្ញាបនបត្រមិនត្រូវបញ្ជាក់តាមរូបភាពណាមួយ បង្ហាញថាបុគ្គល ឬ អង្គភាពរបស់ខ្លួនមានវិញ្ញាបនបត្រឡើយ ។

ជំពូកទី ៩

បទប្បញ្ញត្តិដោយឡែក

មាត្រា ៤៧.-

ផលិតផល ឬ ខ្សែសង្វាក់ផលិតកម្មដែលអនុលោមតាមស្តង់ដារ ឬ ប្រើសញ្ញាសម្គាល់ដូចមានចែងក្នុងការកំណត់នៅក្នុងច្បាប់នេះ មិនត្រូវលើកជាលេសមកអះអាងដើម្បីតវ៉ាប្រឆាំងទៅនឹងបទប្បញ្ញត្តិនៃច្បាប់នេះបានឡើយ ។

មាត្រា ៤៨.-

គ្មានបុគ្គល ឬ អង្គភាពណាមួយអាចផ្សព្វផ្សាយពាណិជ្ជកម្មអំពីការទទួលវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធណាមួយ ទោះបីអង្គភាពនោះបានទទួលវិញ្ញាបនបត្រចេញដោយអង្គភាពចេញវិញ្ញាបនបត្រនៅក្នុងប្រទេស ឬ ក្រៅប្រទេសក៏ដោយ វៀរលែងតែបានចុះបញ្ជី និងបានទទួលទិដ្ឋាការពីវិទ្យាស្ថានស្តង់ដារកម្ពុជា ។

មាត្រា ៤៩.-

ត្រូវហាមឃាត់ចំពោះសកម្មភាពដូចខាងក្រោម :

ក-ធ្វើអាជីវកម្មដោយប្រើឈ្មោះដែលមានពាក្យ **ស្តង់ដារកម្ពុជា** ឬ អក្សរកាត់ ISC ។

ខ-ចុះបញ្ជីពាណិជ្ជសញ្ញាណាដែលមានពាក្យ **ស្តង់ដារកម្ពុជា** នៅក្រោមច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ។

គ-បោះពុម្ព ឬ ថតចម្លងឯកសារស្តង់ដារកម្ពុជា វៀរលែងតែមានការអនុញ្ញាតពីវិទ្យាស្ថាន ។

ជំពូកទី ១០
ទោសប្បញ្ញត្តិ

មាត្រា ៥០.-

បុគ្គលណាមួយដែលប្រើប្រាស់ពាណិជ្ជសញ្ញា ដែលដូចគ្នានឹងសញ្ញាស្តង់ដារដែលបានប្រកាសស្របតាមមាត្រា ២០ នៃច្បាប់នេះ ឬ ប្រើប្រាស់ពាណិជ្ជសញ្ញាណាដែលស្ទើរតែដូចគ្នាទាំងស្រុងធ្វើឱ្យច្រឡំគ្នាទៅនឹងសញ្ញាស្តង់ដារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីប្រាំមួយ (៦)ថ្ងៃ ដល់មួយ(១)ខែ និងពិន័យជាប្រាក់ចំនួនពីហាសិបម៉ឺន (៥០០.០០០)រៀល ទៅពីរលាន(២.០០០.០០០)រៀល ឬ ទោសណាមួយនៃទោសទាំងពីរ ។

មាត្រា ៥១.-

អ្នកកាន់អាជ្ញាប័ណ្ណ ដែលមិនបានដាក់តាំងអាជ្ញាប័ណ្ណរបស់ខ្លួន នៅកន្លែងដែលអាចមើលឃើញបានច្បាស់នៅក្នុងទីតាំងផលិតដែលបានបញ្ជាក់ក្នុងអាជ្ញាប័ណ្ណ ឬ មិនបានសុំអាជ្ញា-

ប័ណ្ណទុតិយតា ពីវិទ្យាស្ថានក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ គិតចាប់ពីថ្ងៃដែលដឹងឮជាសាធារណៈអំពីអាជ្ញាប័ណ្ណរបស់ខ្លួនត្រូវបាត់ឬខូចខាតទាំងស្រុង ឬ មិនបានសុំអាជ្ញាប័ណ្ណថ្មីពីវិទ្យាស្ថាន មុនដំណើរការផលិតនៅពេលមានការផ្លាស់ប្តូរទីតាំងផលិត ឬ បង្កើតសាខា ឬ ពង្រីកផលិតកម្ម ត្រូវពិន័យជាប្រាក់ចំនួនពីហាសិបម៉ឺន (៥០០.០០០)រៀល ទៅពីរលាន (២.០០០.០០០)រៀល ។

មាត្រា ៥២.–

បុគ្គលណាផ្សព្វផ្សាយពាណិជ្ជកម្មអំពីការទទួលវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធណាមួយដែលមិនបានចុះបញ្ជីនិងបានទទួលទិដ្ឋាការពីវិទ្យាស្ថានស្តង់ដារកម្ពុជា ត្រូវពិន័យជាប្រាក់ចំនួនពីហាសិបម៉ឺន (៥០០.០០០)រៀល ទៅពីរលាន (២.០០០.០០០)រៀល ។

មាត្រា ៥៣.–

បុគ្គលណាមួយដែលធ្វើអាជីវកម្មដោយប្រើឈ្មោះដែលមានពាក្យ **ស្តង់ដារកម្ពុជា** ឬ អក្សរកាត់ISC ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីប្រាំមួយ(៦)ថ្ងៃ ដល់មួយ(១) ខែ និងពិន័យជាប្រាក់ចំនួនពីហាសិបម៉ឺន (៥០០.០០០)រៀល ទៅពីរលាន (២.០០០.០០០)រៀល ឬ ទោសណាមួយនៃទោសទាំងពីរ ។

មាត្រា ៥៤.–

នៅពេលមានការកំណត់ស្តង់ដារថ្មីមួយ ឬ ក៏មានការកែប្រែស្តង់ដារណាមួយ អ្នកកាន់អាជ្ញាប័ណ្ណដែលមានប្រើសញ្ញាស្តង់ដារ ដោយអនុលោមតាមស្តង់ដារចាស់មិនបានសុំការអនុញ្ញាតពីវិទ្យាស្ថាន ឬ ប្រើហួសកាលបរិច្ឆេទកំណត់របស់វិទ្យាស្ថាន ត្រូវពិន័យជាប្រាក់ចំនួនពីមួយលាន (១.០០០.០០០)រៀល ទៅប្រាំលាន (៥.០០០.០០០)រៀល ។

មាត្រា ៥៥.–

បុគ្គលណាមួយដែលផលិត ឬ កែច្នៃ ឬ នាំចូលផលិតផល ឬ ផ្សព្វផ្សាយពាណិជ្ជកម្ម លក់ ឬ តម្កល់ផលិតផលណាមួយ ដែលមានបិទសញ្ញាស្តង់ដារក្លែងបន្លំក្នុងគោលបំណងបំភ័ន្ត [illegible]ឱ្យជឿថា ផលិតផលរបស់ខ្លួនមានអាជ្ញាប័ណ្ណនិងបានអនុលោមតាមស្តង់ដារកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ(១)ខែ ដល់បី(៣)ខែ និងពិន័យជាប្រាក់ចំនួន

ពីពីរលាន (២.០០០.០០០)រៀល ទៅប្រាំមួយលាន(៦.០០០.០០០)រៀល ឬទោសណាមួយនៃទោសទាំងពីរ ។

មាត្រា ៥៦.-

បុគ្គលណាមួយដែលផ្សព្វផ្សាយ ឬ ប្រើប្រាស់វិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ ឬ សញ្ញាបញ្ជាក់ប្រព័ន្ធណាមួយក្លែងបន្លំក្នុងគោលបំណងបំភ័ន្តសាធារណជនឱ្យជឿថា ប្រព័ន្ធរបស់ខ្លួនមានវិញ្ញាបនបត្រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ(១)ខែ ដល់បី(៣)ខែ និងពិន័យជាប្រាក់ចំនួនពីពីរលាន (២.០០០.០០០)រៀល ទៅប្រាំមួយលាន (៦.០០០.០០០)រៀល ឬទោសណាមួយនៃទោសទាំងពីរ ។

មាត្រា ៥៧.-

បុគ្គល ឬ អង្គភាពដែលផ្សព្វផ្សាយឬប្រើប្រាស់វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬ វិញ្ញាបនបត្រចុះបញ្ជីក្លែងបន្លំ ក្នុងគោលបំណងបំភ័ន្តសាធារណជនឱ្យជឿថា បុគ្គល ឬអង្គភាពរបស់ខ្លួនបានទទួលការវាយតម្លៃទទួលស្គាល់ ឬ បានចុះបញ្ជី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ(១)ខែ ដល់បី(៣)ខែ និងពិន័យជាប្រាក់ចំនួនពីពីរលាន (២.០០០.០០០) រៀល ទៅប្រាំមួយលាន (៦.០០០.០០០)រៀល ឬ ទោសណាមួយនៃទោសទាំងពីរ ។

មាត្រា ៥៨.-

បុគ្គលណាមួយដែលបោះពុម្ព ឬ ថតចម្លងឯកសារស្តង់ដារកម្ពុជា ដោយមិនមានការអនុញ្ញាតពីវិទ្យាស្ថាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ(១)ខែ ដល់បី(៣)ខែ និងពិន័យជាប្រាក់ចំនួនពីពីរលាន(២.០០០.០០០)រៀល ទៅប្រាំមួយលាន (៦.០០០.០០០)រៀល ឬទោសណាមួយនៃទោសទាំងពីរ ។

មាត្រា ៥៩.-

បុគ្គលណាមួយដែលផលិត ឬ កែច្នៃ ឬ នាំចូលផលិតផល ឬ ផ្សព្វផ្សាយពាណិជ្ជកម្ម ឬ ផលិតផលណាមួយ ដែលមានស្តង់ដារប្រភេទស្តង់ដារបញ្ជា ដែលបានប្រកាសដូចមានចែងក្នុងមាត្រា ១៦ នៃច្បាប់នេះ និងក្រោយកាលបរិច្ឆេទចូលជាធរមានដែលបានកំណត់ក្នុងប្រកាសនោះរួចហើយ មិនមានបិទសញ្ញាស្តង់ដារ ឬ គ្មានអាជ្ញាប័ណ្ណ ឬ

មិនអនុលោមតាមស្តង់ដារបញ្ញានោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ(១)ខែ ដល់មួយ (១)ឆ្នាំ និងពិន័យជាប្រាក់ចំនួនពីពីរលាន (២.០០០.០០០)រៀល ទៅម្ភៃបួនលាន (២៤.០០០.០០០)រៀល ឬ ទោសណាមួយនៃទោសទាំងពីរ ។

មាត្រា ៦០.-

បុគ្គលណាមួយផ្សព្វផ្សាយពាណិជ្ជកម្មឈត់ ឬ ឈត់ផលិតផលណាមួយ ដែលមានប្រើ ឬ បិទសញ្ញាស្តង់ដារដែលខ្លួនដឹងថាអាជ្ញាប័ណ្ណត្រូវលុបចោល ឬ ព្យួរ ឬ ដកហូត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ(១)ខែ ដល់មួយ(១)ឆ្នាំ និងពិន័យជាប្រាក់ចំនួនពីពីរលាន (២.០០០.០០០)រៀល ទៅម្ភៃបួនលាន (២៤.០០០.០០០)រៀល ឬ ទោសណាមួយនៃទោសទាំងពីរ ។

មាត្រា ៦១.-

នៅពេលវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធគ្រប់គ្រងណាមួយត្រូវព្យួរ ឬ ដកហូត អ្នកកាន់វិញ្ញាបនបត្រដែលបញ្ជាក់ ឬ បង្ហាញតាមរូបភាពណាមួយថា ប្រព័ន្ធគ្រប់គ្រងនោះមានវិញ្ញាបនបត្រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ(១)ខែ ដល់មួយ(១)ឆ្នាំ និងពិន័យជាប្រាក់ចំនួនពីពីរលាន (២.០០០.០០០)រៀល ទៅម្ភៃបួនលាន (២៤.០០០.០០០)រៀល ឬទោសណាមួយនៃទោសទាំងពីរ ។

មាត្រា ៦២.-

បុគ្គលណាមួយផ្សព្វផ្សាយ ឬ ប្រើប្រាស់វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជី នៅពេលដែលវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជីត្រូវព្យួរទុក ឬ ដកហូត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ(១)ខែ ដល់មួយ(១)ឆ្នាំ និងពិន័យជាប្រាក់ចំនួនពីពីរលាន (២.០០០.០០០)រៀល ទៅម្ភៃបួនលាន (២៤.០០០.០០០)រៀល ឬ ទោសណាមួយនៃទោសទាំងពីរ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

មាត្រា ៦៣.–

បន្ថែមពីលើទោសពិន័យ ឬពន្ធនាគារ បុគ្គលណាដែលប្រព្រឹត្តល្មើសដូចមានចែងក្នុងមាត្រា ៥៩ និងមាត្រា ៦០ នៃច្បាប់នេះ តុលាការអាចសម្រេចរឹបអូសនូវផលិតផលល្មើសទាំងអស់ ឬ មួយផ្នែក ។

មាត្រា ៦៤.–

ក្នុងករណីមិនរាងចាលចំពោះបទល្មើសនឹងមាត្រា ៥០ មាត្រា ៥១ មាត្រា ៥២ មាត្រា ៥៣ មាត្រា ៥៤ មាត្រា ៥៥ មាត្រា ៥៦ មាត្រា ៥៧ មាត្រា ៥៨ មាត្រា ៥៩ មាត្រា ៦០ មាត្រា ៦១ និងមាត្រា ៦២ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសទ្វេឡើង ទាំងការផ្តន្ទាទោសពិន័យជាប្រាក់ ទាំងការផ្តន្ទាទោសដាក់ពន្ធនាគារ ដោយពុំទាន់គិតបញ្ចូលនូវទោសព្រហ្មទណ្ឌធ្ងន់ធ្ងរចំពោះបច្ច័យនៃបទល្មើសដែលបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាព សុវត្ថិភាព ឬ ដល់អាយុជីវិតរបស់អ្នកប្រើប្រាស់ ។

មាត្រា ៦៥.–

ជនណាដែលរារាំងអធិការក្នុងពេលបំពេញភារកិច្ច ត្រូវពិន័យជាប្រាក់ចំនួនពីមួយលាន (១.០០០.០០០)រៀល ទៅប្រាំលាន (៥.០០០.០០០)រៀល ។

មាត្រា ៦៦.–

ជនណាដែលក្លែងបន្លំខ្លួនជាអធិការ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ(១)ខែ ដល់មួយ(១)ឆ្នាំ និងពិន័យជាប្រាក់ចំនួនពីហាសិបម៉ឺន (៥០០.០០០)រៀល ទៅពីរលាន (២.០០០.០០០)រៀល ឬ ទោសណាមួយនៃទោសទាំងពីរ ។

មាត្រា ៦៧.–

អធិការដែលមានចែងក្នុងមាត្រា ៧ នៃច្បាប់នេះ ត្រូវទទួលខុសត្រូវចំពោះទណ្ឌកម្មរដ្ឋបាល ។

អធិការត្រូវទទួលខុសត្រូវចំពោះការធ្វេសប្រហែស ដែលបណ្តាលឱ្យមានការថ្លោះធ្លោយ និងបច្ច័យផ្សេងៗដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

ទណ្ឌកម្មរដ្ឋបាលដែលមានចែងខាងលើនេះ មិនធ្វើជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាឡើយ ប្រសិនបើមានបទល្មើសណាមួយត្រូវប្រព្រឹត្ត ។

មាត្រា ៦៨.-

ទណ្ឌកម្មរដ្ឋបាលដែលត្រូវយកមកអនុវត្តចំពោះអធិការរួមមាន ៖

ក-ទណ្ឌកម្មរដ្ឋបាលកម្រិតដំបូងគឺការព្រមាន ឬ ការស្តីបន្ទោសពីប្រធាន ។

ខ-ទណ្ឌកម្មរដ្ឋបាលកម្រិតមធ្យមគឺការបញ្ឈប់ការផ្តល់ប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗទៀត ក្នុងរយៈពេលចាប់ពីប្រាំមួយ(៦)ខែឡើងទៅ ។

គ-ទណ្ឌកម្មរដ្ឋបាលកម្រិតធ្ងន់គឺការដកហូតតួនាទី ឬ មុខតំណែង ឬ ការបញ្ឈប់ពីការងារតែម្តង ។

ទណ្ឌកម្មរដ្ឋបាលដែលមានចែងខាងលើនេះ នៅពុំទាន់គិតដល់បទល្មើសព្រហ្មទណ្ឌ និងសំណងរដ្ឋប្បវេណីផ្សេងៗទៀត ។

ជំពូកទី ១១

អវសានប្បញ្ញត្តិ

មាត្រា ៦៩.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០០៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ពរម.០៧០៦.២៦២

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ហត្ថលេខា

ស៊ុយ សែម

លេខ: ២៥៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០៧

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ប៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៦០៧/២២៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរិវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំង :

១-ឯកឧត្តម ម៉ុន ឌុន្នា ជាទីប្រឹក្សាផ្ទាល់អគ្គលេខាធិការព្រឹទ្ធសភា សំរាប់នីតិកាលទី២ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

២-ឯកឧត្តម ញ៉ែម វ៉ែន ជាទីប្រឹក្សាផ្ទាល់អគ្គលេខាធិការព្រឹទ្ធសភា សំរាប់នីតិកាលទី២ មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៧
តាមព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

៣.៧.០៧០៦.២៣៥

លេខ ៦៧៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៦០៧/២៣២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ហ្សានីញេ រ៉ូសេ្ស លូី ស្សូសែហ្វ** (ZANNIER ROGER LOUIS JOSEPH) ជនជាតិបារាំង សញ្ជាតិបារាំង កើតថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ១៩៤៤ នៅសាំងសាម៉ុងដ៍ ប្រទេសបារាំង ។

មាត្រា២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៧

ត្អូងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ជករ

ជា ស៊ីម

៣រល.០៧០៦.២៤៤

លេខៈ ៦៣៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០០៧

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៦០៧/២៤០

យើង

ការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជា ឆ្នាំ២០០៧

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក.ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០ នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែ ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០២ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥, ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៦
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០៣ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798

- បានឃើញក្រឹត្យលេខ៩៧ក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធលើទំនិញ នាំចេញនាំចូល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០០ ដែលបានប្រកាស ឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០០១
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាអន្តរជាតិ ស្តីពីការធ្វើឱ្យស៊ីចង្វាក់គ្នានៃការកំណត់មុខទំនិញ និងប្រព័ន្ធលេខកូដ
- បានឃើញពិធីសារស្តីពីការអនុវត្តនាមវលី នៃតារាងពន្ធគយស៊ីចង្វាក់គ្នារបស់អាស៊ាន ដែលចុះហត្ថលេខា ដោយរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៣ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន
- បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០១ ស្តីពីការកែសម្រួលអត្រាពន្ធ និងអាករគយលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ អាករពិសេស លើទំនិញ និងសេវាមួយចំនួន និងអាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ និងអាករពិសេសលើទំនិញមួយចំនួន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

ប្រការ ១ : ដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជាឆ្នាំ២០០៧ ដូចមានភ្ជាប់ជាមួយនេះ ដែលបានរៀបចំដោយអនុលោមតាមប្រព័ន្ធស៊ីចង្វាក់ នៃការកំណត់មុខទំនិញ និងប្រព័ន្ធលេខកូដ និងស្របទៅតាមតារាងពន្ធគយ នៃប្រព័ន្ធស៊ីចង្វាក់របស់អាស៊ាន (AHTN 2007) ចាប់ពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០០៧ តទៅ ។

ប្រការ ២ : រាល់មុខទំនិញនាំចេញ នាំចូលត្រូវជាប់ពន្ធនាំចូល អាករពិសេស អាករលើតម្លៃបន្ថែម និងអាករនាំចេញ ដូចមានចែងលំអិតក្នុងតារាងពន្ធគយនេះ ។

ប្រការ ៣ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៧ ខាងមុខនេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន ខេត្តក្រុង "ដើម្បីជូនជ្រាប"
- សភាពាណិជ្ជកម្ម
- ទីចាត់ការគយ និងរដ្ឋាករ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីចាត់ការគយនិងរដ្ឋាករ
លេខៈ ៦៧៤ គ.រ

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០០៧

សូមគោរពជូន

ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

កម្មវត្ថុៈ សំណើសុំកែតម្រូវកំហុសបច្ចេកទេសមួយចំនួនលើតារាងពន្ធគយកម្ពុជាឆ្នាំ២០០៧។

យោងៈ -ប្រកាសលេខ ៨៦៥សហវ ចុះថ្ងៃទី១២ ខែមិថុនា ខែឆ្នាំ២០០៧ ស្តីពីការដាក់ឲ្យប្រើប្រាស់តារាងពន្ធគយឆ្នាំ ២០០៧ និងលិខិតលេខ ០៣៩សហវ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសជំរាបជូនឯកឧត្តមទេសរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្នុងដំណើរការធ្វើសេចក្តីព្រាងតារាងពន្ធគយកម្ពុជាឆ្នាំ២០០៧ ដោយផ្ទេរពីតារាងពន្ធគយកម្ពុជាឆ្នាំ២០០៤ ឲ្យស្របតាមតារាងពន្ធគយស៊ីសង្វាក់អាស៊ានឆ្នាំ២០០៧ (AHTN 2007) នោះមានការកើតឡើងនូវកំហុសផ្លូវបច្ចេកទេស អក្ខរាវិរុទ្ធគួរឲ្យសោកស្តាយចំនួនប្រាំពីរបន្ទាត់អត្រា ដែលតម្រូវឲ្យមានការកែសំរួលឲ្យបានត្រឹមត្រូវឡើងវិញតាមបន្ទាត់អត្រា និងអត្រាពន្ធអាករជាធរមាន ដែលមានលេខកូដ និងសេចក្តីបរិយាយ ដូចខាងក្រោមនេះ :

លេខទំព័រ	លេខកូដទំនិញ	អត្រាពន្ធនិងអាករ ដែលខុស					អត្រាពន្ធនិងអាករកែតម្រូវ				
		ឯកតា	នាំចូល			នាំចេញ	ឯកតា	នាំចូល			នាំចេញ
			CD	ST	VAT			CD	ST	VAT	
130	2203.00.10	LT	35	30	10	0	KG	35	20	10	0
130	2203.00.90	LT	35	30	10	0	KG	35	20	10	0
162	2707.99.20	TNE	7	10	10	0	KG	15	10	10	0
163	2710.11.30	TNE	35 0.02$/l	33.33	10	0	KG	15	5	10	0
163	2710.11.40	TNE	15	5	10	0	KG	35 0.02$/l	33.33	10	0
164	2710.19.16	TNE	7	0	10	0	KG	7	10	10	0
164	2710.19.79	TNE	15 0.04$/l	4.35	10	0	KG	7	0	10	[illegible]

សេចក្តីបរិយាយ

ទំព័រ	ស្រាបៀរម៉ាលត៍	
130	2203.00.10	- ស្រាបៀរពណ៌ខ្មៅ និងភេសជ្ជៈផតធ័រ
130	2203.00.90	- ស្រាបៀរផ្សេងទៀត រួមទាំងភេសជ្ជៈអាលេ (ភេសជ្ជៈស្រដៀងស្រាបៀរ)
	ផលិតផលគេលសិលា	
162	2707.99.20	- - - កាបោនខ្មៅ
163	2710.11.30	- - - ប្រេងសាំងក្រអូប
163	2710.11.40	- - - តេត្រាប្រូពីលែន
164	2710.19.16	- - - - ប្រេងកាត
164	2710.19.79	- - - - ប្រេង F.O ផ្សេងទៀត

អាស្រ័យហេតុនេះ សូមឯកឧត្តមទេសរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចដោយអនុគ្រោះ ។

សូមឯកឧត្តមទេសរដ្ឋមន្ត្រី មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំ ។

ត.ទ.ប្រធានអគ្គនាយកដ្ឋានគយ

ទទួលបន្ទុក[illegible]ចាត់ការគយនិងរដ្ឋាករ

[illegible] ១

29/6/07

សៀង ឈុនគ្រី

វិធានទូទៅ

វិធានទូទៅសំរាប់បកស្រាយឈ្មោះទំនិញនៅក្នុងតារាងពន្ធគយ

ការចាត់ថ្នាក់ទំនិញនៅក្នុងតារាងពន្ធគយត្រូវធ្វើឡើងដោយអនុលោមទៅតាមគោលការណ៍ដូចតទៅ :

វិធានទី ១

ចំណងជើងរបស់ផ្នែក ជំពូក ឬជំពូករង គឺគ្រាន់តែផ្តល់ភាពងាយស្រួលសំរាប់តែចង្អុលបង្ហាញប៉ុណ្ណោះ ។ ការចាត់ថ្នាក់ត្រូវបានកំណត់ដោយស្របច្បាប់ ដោយយោងទៅតាមស័ព្ទ នៃទីតាំង និងកំណត់សំគាល់នៃផ្នែក ឬជំពូក និងវិធានដូចខាងក្រោម កាលបើទំនិញទាំងនោះ មិនផ្ទុយពីសព្ទនៃទីតាំង និងកំណត់សំគាល់នោះទេ ។

បំណកស្រាយវិធាន ១

(I). នាមវល្លីដែលមានទំរង់ជាប្រព័ន្ធទំនិញដែលបានប្រើប្រាស់នៅក្នុងពាណិជ្ជកម្មអន្តរជាតិ ។ ទំនិញទាំងនេះ ត្រូវបានជុំនៅក្នុងផ្នែក ជំពូក និង ជំពូករង ដែលបានផ្តល់នូវចំណងជើងចង្អុលបង្ហាញយ៉ាងច្បាស់លាស់ប្រភេទនៃទំនិញ ។ ទោះជាយ៉ាងណាក៏ដោយ មានករណីជាច្រើនទំនិញប្រភេទខ្លះ និងមួយចំនួនមិនអាចចាត់ថ្នាក់នៅក្នុងផ្នែកមួយ ឬ ជំពូកមួយ ឬ យោងទៅក្នុងចំណងជើងមួយបានទេ ។

(II). ដូចនេះ វិធានទី ១ ចំណងជើងគ្រាន់តែផ្តល់ "ភាពងាយស្រួលសំរាប់ចង្អុលបង្ហាញតែប៉ុណ្ណោះ" ។ ដោយហេតុនេះ វាមិនមានលក្ខណៈស្របច្បាប់ នៃការចាត់ថ្នាក់ទេ ។

(III). ផ្នែកទីពីរនៃវិធាននេះផ្តល់ថា ការចាត់ថ្នាក់ត្រូវកំណត់ :

(ក). យោងតាមស័ព្ទនៃទីតាំង និងកំណត់សំគាល់ផ្នែក ឬជំពូកណាមួយ និង

(ខ). ដោយលក្ខណៈសមស្រប ត្រូវយោងទៅវិធានទី ២, ៣ ,៤ និង ៥ បើសិនជាមិនមានចែងនៅទីតាំងឬកំណត់សំគាល់ទាំងនេះ ។

(IV). ខដែលមានចែងនៅបំណកស្រាយ (៣ក) គឺជាការជាក់ស្តែង និងទំនិញជាច្រើនត្រូវបានចាត់ថ្នាក់នៅក្នុងនាមវល្លីដោយមិនចាំបាច់ការពិចារណាបន្ថែមលើបំណកស្រាយវិធានទេ (ឧទា. សេះរស់ (ទីតាំងលេខ ០១.០១) ទំនិញឱសថបានបញ្ជាក់ច្បាស់នៅក្នុងកំណត់សំគាល់ទី ៤ ទៅក្នុងជំពូកទី ៣០ (ទីតាំង ៣០.០៦)) ។

(V). ខដែលមានចែងនៅក្នុងបំណងស្រាយ (៣ខ) ពាក្យថា "ទីតាំងឬកំណត់សំគាល់ដែលមិនមានចែងនៅកន្លែងដទៃ" គឺមានបំណងធ្វើអោយវាកាន់តែច្បាស់ស័ព្ទនៃចំណងជើងទីតាំង និងកំណត់សំគាល់ផ្នែក ឬជំពូកដែលទាក់ទងណាមួយគឺជាការប្រសើរ មានន័យថា គេគឺ

ជាការពិចារណាលើកទីមួយនៅក្នុងការកំណត់ការចាត់ថ្នាក់ ។ ឧទាហរណ៍ នៅក្នុងជំពូកទី ៣១ កំណត់សំគាល់បានបង្ហាញថា ទីតាំងពិតប្រាកដទាក់ទងទៅនឹងទំនិញជាក់លាក់ណាមួយតែប៉ុណ្ណោះ ។ ហេតុដូចនេះហើយ ទីតាំងទាំងនេះមិនអាចពង្រីកបន្តដោយរាប់បញ្ចូលនូវទំនិញដែលអាចចាត់ថ្នាក់ផ្សេងពីនេះ ដោយហេតុផលនៃការអនុវត្តវិធានទី ២ខ ។

វិធានទី ២

ក- សេចក្តីយោងទាំងឡាយចំពោះវត្ថុនៅក្នុងទីតាំងមួយ គឺរាប់បញ្ចូលវត្ថុ ដែលមិនគ្រប់គ្រឿង ឬមិនទាន់សំរេច ឱ្យតែវត្ថុទាំងនោះ បានបង្ហាញថា មានលក្ខណៈសំខាន់អាចចាត់ជាវត្ថុគ្រប់គ្រឿង ឬវត្ថុសំរេចហើយ ។ សេចក្តីយោងទាំងនេះ ក៏ចាត់បញ្ចូលផងដែរ ថាជាវត្ថុគ្រប់គ្រឿងឬវត្ថុសំរេច (ឬចាត់ថ្នាក់ជាវត្ថុគ្រប់គ្រឿង ឬវត្ថុសំរេច យោងតាមខ្លឹមសារវិធាននេះ)នៅពេលដែលវត្ថុទាំងនោះបានបង្ហាញក្នុងស្ថានភាពដោះជាបំណែក ឬមិនទាន់តំឡើង ។

ខ- សេចក្តីយោងទាំងឡាយចំពោះវត្ថុធាតុ និងសារធាតុចូលក្នុងទីតាំងណាមួយ គឺវាពាក់ព័ន្ធទៅនឹងល្បាយឬបន្សំ នៃវត្ថុឬសារធាតុនោះទៅនឹងវត្ថុឬសារធាតុដទៃ ។ ដូចគ្នានេះដែរ គ្រប់និទ្ទេសនៃវត្ថុធាតុឬធាតុ ត្រូវបានបញ្ចូលទៅនឹងស្នាដៃវត្ថុនោះ ទោះបីជាបានបង្កើតពីវត្ថុធាតុនោះទាំងស្រុងឬភាគខ្លះក៏ដោយ ។ ការចាត់ថ្នាក់នៃវត្ថុល្បាយ ឬវត្ថុផ្សំទាំងនេះ ធ្វើទៅតាមគោលការណ៍ដែលចែងក្នុងវិធានទី ៣ ។

បំណកស្រាយវិធាន ២

បំណកស្រាយវិធានទី ២ក

(វត្ថុគ្រប់គ្រឿង ឬមិនទាន់សំរេច)

(I). ផ្នែកដំបូងនៃវិធានទី១ មានវិសាលភាពលើទីតាំងទាំងឡាយនៃវត្ថុជាក់លាក់ណាមួយ គឺមិនត្រឹមតែវត្ថុគ្រប់គ្រឿងប៉ុណ្ណោះទេ ក៏ប៉ុន្តែរួមទាំងវត្ថុមិនគ្រប់គ្រឿង ឬមិនទាន់សំរេចទៀតផង នៅពេលដែលវាមានលក្ខណៈពិសេសថាជាវត្ថុគ្រប់គ្រឿង ឬវត្ថុសំរេច ។

(II). ខដែលមានចែងនៅក្នុងវិធាននេះ ក៏ត្រូវបានអនុវត្តផងដែរចំពោះ វត្ថុមិនទាន់ប្រើប្រាស់ លុះត្រាតែវាត្រូវចែងនៅក្នុងទីតាំងណាមួយច្បាស់លាស់ ។ ពាក្យ "វត្ថុមិនទាន់ប្រើប្រាស់" មានន័យថា វត្ថុមិនទាន់យកទៅប្រើប្រាស់ ហើយមានរូបរាងប្រហាក់ប្រហែល ឬទំរង់វត្ថុសំរេច ឬជាភាគ ដែលអាចយកទៅប្រើប្រាស់បានសំរាប់ការបំពេញវត្ថុសំរេច ឬភាគ លើកលែងតែករណីពិសេសមួយចំនួន ។

ផលិតផលពាក់កណ្តាលសំរេចមិនទាន់មានរូបរាងងសំខាន់របស់វត្ថុសំរេច(ដូចជាដុំដែកមានរាងទ្រវែង, វង្វង់, បំពង់ ។ល។ មិនត្រូវបានចាត់ថាជា"វត្ថុមិនទាន់ប្រើប្រាស់"ទេ ។

(III). ដោយឃើញថា ទំហំនៃទីតាំងទាំងឡាយនៃផ្នែក I ទៅ IV ផ្នែកនៃវិធាននេះ មិនត្រូវបានអនុវត្តជាទូទៅចំពោះទំនិញនៅក្នុងផ្នែកទាំងឡាយនេះ ។

(IV). មានករណីជាច្រើននៅក្នុងវិធាន ត្រូវបានរៀបរាប់នៅក្នុងកំណត់សំគាល់នៃបំណកស្រាយទូទៅរបស់ផ្នែក ឬជំពូក (ឧទាហរណ៍ ផ្នែកទី XVI ឬ ជំពូក ៦១, ៦២, ៨៦, ៨៧ និង ៩០) ។

បំណកស្រាយវិធានទី ២ក

(វត្ថុដែលមិនទាន់តំឡើង ឬដោះជាបំណែក)

(V). ផ្នែកទីពីរនៃវិធានទី ២ក បដិញ្ញតប្ញថែងថា វត្ថុគ្រប់គ្រឿងឬវត្ថុសំរេច ដែលបង្ហាញថា មិនទាន់តំឡើងឬដោះជាបំណែក ត្រូវបានចាត់ថ្នាក់ដូចទីតាំងរបស់វត្ថុដែលតំឡើងរួច ។ ពេលដែលទំនិញមកជាមួយភាពមានមុខងារសំរាប់ខ្ចប់, លើកដាក់ ឬសំរាប់ដឹកជញ្ជូន ។

(VI). វិធាននេះក៏អនុវត្តផងដែរចំពោះវត្ថុមិនគ្រប់គ្រឿង ឬមិនទាន់សំរេច ដែលនៅជាមិនទាន់តំឡើងឬដោះជាបំណែក ត្រូវបានចាត់ដូចវត្ថុគ្រប់គ្រឿងឬសំរេច ដោយយោងតាមលក្ខណៈ ផ្នែកដំបូង នៃវិធាននេះ ។

(VII). តាមអត្ថន័យនៃវិធាននេះ "វត្ថុដែលមិនទាន់តំឡើង ឬដោះជាបំណែក" មានន័យថា វត្ថុដែលសមាសភាគត្រូវបានតំឡើងដោយគ្រឿងឬឧបករណ៍សាមញ្ញ ឧទាហរណ៍ ទួណឺវីស, ក្បាលឡោស៊ី ប៊ូឡុង...។ល។ ឬដោយមីននិងផ្សារ ។ សមាសភាគនៃវត្ថុមិនទាន់តំឡើងដែលលើសពីតំរូវការប្រើប្រាស់ត្រូវចាត់ថ្នាក់ក្នុងទីតាំងដទៃ ។

(VIII). ករណីមួយចំនួននៅក្នុងវិធាន ត្រូវបានចែងក្នុងកំណត់សំគាល់នៃបំណកស្រាយទូទៅរបស់ផ្នែក ឬជំពូក (ឧទាហរណ៍ ផ្នែកទី XVI និងជំពូកទី ៨៤, ៨៦, ៨៧ និង ៨៩)

(IX). ដោយឃើញថា ទំហំនៃទីតាំងទាំងឡាយនៃផ្នែក I ទៅ IV ផ្នែកនៃវិធាននេះ មិនត្រូវបានអនុវត្តជាទូទៅចំពោះទំនិញនៅក្នុងផ្នែកទាំងឡាយនេះ ។

បំណកស្រាយវិធានទី ២ខ

(ល្បាយ និងសមាសធាតុផ្សំ ឬសារធាតុ)

(X). វិធានទី ២ខ ចែងអំពីល្បាយ និងសមាសធាតុផ្សំ ឬសារធាតុនៃទំនិញដែលមានពីរ ឬច្រើនសារធាតុ ឬសមាសធាតុ ។ ទីតាំងដែលមានសារធាតុ ឬសមាសធាតុនៅក្នុងទីតាំងតែម្តង ដូចជាទីតាំងលេខ ០៥.០៣ (សក់សេះ) និង ៤៥.០៣ (វត្ថុបានមកពីឆ្នុកក្រាចធម្មជាតិ)។

ចូរកត់សំគាល់ថា វិធាននេះក៏អនុវត្តផងដែរ ប្រសិនបើកំណត់សំគាល់ទីតាំង ឬផ្នែក ឬជំពូក មិនមានចែងនៅកន្លែងផងៃ ឧទា.ទីតាំងលេខ ១៥.០៣ ខ្លាញ់ជ្រូក, មិន..លាយ។ ល្បាយបានរៀបចំជាស្រេចដូចមានចែងក្នុងអត្ថបទនៃកំណត់សំគាល់ផ្នែកឬជំពូក ឬទីតាំង ត្រូវបានចាត់ថ្នាក់ដោយអនុលោមទៅតាមវិធានទី ១ ។

(XI) . ការអនុវត្តវិធាននេះ ដើម្បីពង្រីកនូវការយោងទាំងឡាយរបស់សារធាតុ ឬសមាសធាតុ ចំពោះទីតាំងដោយធ្វើការរួមបញ្ចូលល្បាយ ឬការលាយចូលគ្នាជាមួយសារធាតុ ឬសមាសធាតុផ្សេងទៃទៀត។ វិធានក៏អនុវត្តផងដែរចំពោះទំនិញដែលមានតែមួយផ្នែករបស់សារធាតុ ឬសមាសធាតុ ។

(XII) . ទោះជាយាងណាក៏ដោយ វិធាននេះ មិនអាចពង្រីកទីតាំងគ្របដណ្តប់ទំនិញដែលមិនមានចែងនៅក្នុងវិធានទី១ទេ ក្នុងការឆ្លើយតបទៅនឹងការបរិយាយនៃទីតាំង។ វាអនុវត្តតែនៅពេលណាមានបន្ថែមវត្ថុធាតុ ឬសារធាតុផ្សេងទៀត បង្ខូចនូវលក្ខណៈទំនិញនៃប្រភេទទំនិញដែលបានលើកឡើងនៅក្នុងទីតាំង ។

(XIII) . ជាផលវិបាកនៃវិធាននេះ ល្បាយ ឬការលាយចូលគ្នានិងទំនិញដែលមានសំភារៈ ឬសារធាតុច្រើនបញ្ចូលគ្នា ត្រូវតែចាត់ថ្នាក់ដោយយោងទៅតាមគោលការណ៍នៃវិធានទី ៣ បើសិនជាទំនិញនោះអាចចាត់ថ្នាក់នៅក្នុងទីតាំងពីរ ឬច្រើន ។

វិធានទី ៣

ប្រសិនជាទំនិញឃើញដូចជាត្រូវចាត់ថ្នាក់មានពីរទីតាំង ឬក៏ច្រើនទីតាំងដោយអនុវត្តតាមវិធានទី ២ខ ឬដោយហេតុផលផ្សេងនោះ ការចាត់ថ្នាក់នឹងធ្វើដូចតទៅនេះ :

ក- ទីតាំងណាដែលសមស្របបំផុតត្រូវមានអាទិភាពលើបណ្តាទីតាំងដែលមានន័យទូទៅ ។ ក៏ប៉ុន្តែ កាលបើមានពីរឬច្រើនទីតាំងហើយទីតាំងនីមួយៗពាក់ពន្ធ័ទៅតែមួយភាគប៉ុណ្ណោះ នៃវត្ថុធាតុដែលបង្កើតជាផលិតផលល្បាយណាមួយ ឬវត្ថុផ្សំណាមួយ ឬតែភាគណាមួយ នៃវត្ថុ នៅក្នុងករណីដែលទំនិញបង្ហាញជាសម្រាប់ដើម្បីលក់រាយ ទីតាំងចំពោះផលិតផល ឬវត្ថុទាំងនោះ ត្រូវចាត់ទុកជាពិសេសថាស្មើគ្នា ទោះបីជាទំនិញណាមួយពណ៌នាច្បាស់លាស់ ឬ ពេញលេញជាងក៏ដោយ ។

ខ- ផលិតផលល្បាយ វត្ថុដែលផ្សំដោយវត្ថុធាតុខុសគ្នា ឬក៏បង្កើតឡើងដោយសមាសធាតុផ្សេងៗគ្នា និងទំនិញបង្ហាញជាសម្រាប់ហើយខ្ចប់សំរាប់លក់រាយ ដែលការចាត់ថ្នាក់មិនអាចអនុវត្តតាមវិធានទី ៣ក ខាងលើនេះត្រូវចាត់ថ្នាក់ទៅតាមវត្ថុធាតុ ឬវត្ថុណាមួយដោយដែលមានលក្ខណៈសំខាន់ជាង កាលបើលក្ខណៈវិនិច្ឆ័យនេះ អាចអនុវត្តទៅបាន ។

គ-ក្នុងករណីដែលវិធានទី ៣ក និង ៣ខ មិនអនុញ្ញាតឱ្យធ្វើការចាត់ថ្នាក់បានទេនោះ ទំនិញត្រូវចាត់ថ្នាក់ទៅក្នុងទីតាំងមួយ ដែលនៅក្រោយបំផុតទៅតាមលេខលំដាប់ក្នុងចំណោមទីតាំងដែលយកជាបានការ ។

បំណកស្រាយវិធាន ៣

(I). វិធាននេះផ្តល់វិធីសាស្ត្របីសំរាប់ការចាត់ថ្នាក់មុខទំនិញ (ដែលឃើញជាលើកដំបូង) ដែលអាចនៅក្នុងទីតាំងពីរ ឬច្រើនស្ថិតនៅក្រោមស័ព្ទនៃវិធានទី ២ខ ផង ឬសំរាប់ហេតុផលផ្សេងណាមួយផង ។ វិធីសាស្ត្រទាំងនេះ អនុវត្តតាមលំដាប់ដូចដែលបានដាក់ចេញនៅក្នុងវិធាន ។ ដូចនេះ វិធានទី ៣ខ អនុវត្តបានលុះត្រាតែវិធាន ៣ក មិនអាចធ្វើការចាត់ថ្នាក់បាន ហើយប្រសិនបើវិធាន ៣ក និង ៣ខ មិនអាចអនុវត្តបានត្រូវប្រើវិធានទី ៣គ ។ លំដាប់ដែលមានអាទិភាព គឺ (ក). បរិយាយជាក់លាក់, (ខ). លក្ខណៈសំខាន់, (គ). ទីតាំងដែលមានលំដាប់លេខចុងក្រោយ ។

(II). វិធានដែលមានប្រសិទ្ធិភាព គឺសំរាប់តែកំណត់សំគាល់ទីតាំង ឬផ្នែក ឬជំពូក ដែលមិនមានចែងនៅកន្លែងដទៃ ។ ឧទាហរណ៍ កំណត់សំគាល់ ៤ខ នៃ ជំពូកទី ៩៧ តំរូវឱ្យទំនិញដែលមានការបរិយាយទាំងនៅក្នុងទីតាំងមួយពី ៩៧.០១ ដល់ ៩៧.០៥ និងដែលមានការបរិយាយទាំងនៅក្នុងទីតាំងលេខ ៩៧.០៦ ត្រូវចាត់ថ្នាក់នៅក្នុងទីតាំងមុនដំបូង ។ ទំនិញទាំងនេះ ត្រូវចាត់ថ្នាក់យោងតាមកំណត់សំគាល់ ៤ខ នៃជំពូកទី ៩៧ និង មិនយោងទៅនឹងវិធាននេះទេ ។

បំណកស្រាយវិធាន ៣ក

(III). វិធីសាស្ត្រទី ១ នៃការចាត់ថ្នាក់ដែលមាននៅក្នុងវិធានទី ៣ក គឺផ្តល់នូវការបរិយាយមុខទំនិញយ៉ាងជាក់លាក់បំផុតជាងទីតាំងដែលមានការបរិយាយទូទៅ ។

(IV). វាមិនអាចអនុវត្តបាននូវការដាក់ចេញវិធានដ៏តឹងរឹង និងការពន្យល់លឿនពេកសំរាប់ការកំណត់ថា ទីតាំងមួយបរិយាយពិសេសជាងទីតាំងផ្សេងនោះឡើយ ប៉ុន្តែ ជាទូទៅអាចនិយាយបានថា:

(ក).ការបរិយាយតាមឈ្មោះមានភាពជាក់ច្បាស់ជាងតាមប្រភេទ (ឧទាហរណ៍ ប្រដាប់កោរពុកមាត់ និងកន្ត្រៃកាត់សក់ប្រើដោយម៉ូទ័រអគ្គិសនី ត្រូវចាត់ថ្នាក់ក្នុងទីតាំងលេខ ៨៥.១០ និង ៨៥.០៨ ជាឧបករណ៍មេកានិកប្រើអគ្គិសនី សំរាប់ការប្រើដោយដៃ ឬក្នុងទីតាំងលេខ ៨៥.០៩ សំរាប់ឧបករណ៍មេកានិកប្រើអគ្គិសនីមានម៉ូទ័រប្រើក្នុងផ្ទះ)។

(ខ). បើសិនជាទំនិញត្រូវនឹងការបរិយាយដែលបញ្ជាក់ច្បាស់លាស់អំពីខ្លួនវា នោះការបរិយាយនោះគឺមានភាពជាក់ច្បាស់ជាងការ បរិយាយណាដែលមានការបញ្ជាក់មិនមានភាពពេញលេញ ។

ឧទាហរណ៍ប្រភេទទំនិញខាងក្រោម :

(១). ព្រំធ្វើពីក្រណាត់ត្បាញមានរាងកញ្ចុំ ព្រំនេះសំរាប់ប្រើក្នុងរថយន្ត វាមិនត្រូវចាត់ថ្នាក់ជាបរិក្ខារបន្សំរបស់រថយន្តនៅក្នុងទីតាំងលេខ ៨៧.០៨ ទេ តែវាត្រូវចាត់ថ្នាក់ចូលទៅក្នុងទីតាំងលេខ ៥៧.០៣ ព្រោះវាត្រូវបានបញ្ជាក់ច្បាស់ជាងថាវាជាព្រំ ។

(២). កញ្ចក់ការពារដែលគ្មានគ្រោងរួមមានការធ្វើឱ្យស្វិត ឬបិតភ្ជាប់គ្នាកាត់ជារាងសំរាប់ប្រើប្រាស់ក្នុងយន្តហោះ ដែលមិនត្រូវចាត់ថ្នាក់ដោយថាជាបំណែកនៃទំនិញនៅក្នុងទីតាំងលេខ ៨៨.០១ ឬ ៨៨.០២ ទេ ប៉ុន្តែនៅក្នុងទីតាំងលេខ ៧០.០៧ នៅពេលដែលវាត្រូវបានបញ្ជាក់ច្បាស់ថែមទៀតថា វាជាកញ្ចក់សំរាប់ការពារ ។

(V). ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលទីតាំងពីរ ឬច្រើនដែលមួយៗមានតែបំណែក ឬភាគតែពីរនៃសំភារៈ ឬសារធាតុ ដែលមាននៅក្នុងទំនិញល្បាយឬសមាសធាតុណាមួយនោះ ឬមានតែបំណែកឬភាគតែប៉ុណ្ណោះនៃវត្ថុដែលរៀបចំសំរាប់លក់រាយនោះ ទីតាំងទាំងនោះ ត្រូវចាត់ថា មានលក្ខណៈស្មើគ្នាទាក់ទងទៅនឹងទំនិញនោះ ទោះបីជាទីតាំងមួយក្នុងចំណោមទីតាំងទាំងនោះផ្តល់នូវការបរិយាយពេញលេញ ឬជាក់ច្បាស់ជាងក៏ដោយ ។ ក្នុងករណីនេះ វិធាន ៣ខ ឬ ៣គ ត្រូវប្រើសំរាប់កំណត់នូវចំណាត់ថ្នាក់ទំនិញទាំងនោះ។

បំណកស្រាយវិធាន ៣ខ

(VI). វិធីសាស្ត្រទីពីរនេះទាក់ទងតែជាមួយ :

(១). ផលិតផលល្បាយ

(២). ទំនិញល្បាយដែលរួមមានសំភារៈផ្សេងគ្នា

(៣). ទំនិញល្បាយដែលរួមមានសមាសភាគផ្សំផ្សេងគ្នា

(៤). ទំនិញជាសម្រាប់រៀបចំសំរាប់លក់រាយ

វិធាននេះអនុវត្តទៅបានលុះត្រាតែវិធាន ៣ក មិនអាចអនុវត្តបាន ។

(VII). ក្នុងករណីទាំងនេះទំនិញ ត្រូវបានចាត់ថ្នាក់នៅពេលដែលវាត្រូវធ្វើឡើងដោយវត្ថុធាតុ ឬសមាសភាគដែលបង្ហាញពីលក្ខណៈសំខាន់របស់វា បើលក្ខណៈនេះអាចអនុវត្តបាន ។

(VIII). កត្តាដែលអាចអោយកំណត់បាននូវលក្ខណៈសំខាន់ អាចប្រែប្រួលទៅតាមប្រភេទ នៃទំនិញ ។ ឧទាហរណ៍ វាត្រូវបានកំណត់ដោយលក្ខណៈធម្មជាតិនៃវត្ថុធាតុ ឬសមាសភាគ

តាមរយៈលក្ខណៈចាត់ការ បរិមាណ ទម្ងន់ ឬតំលៃ ឬតាមរយៈតួនាទីរបស់វត្ថុធាតុចំបង ដែលទាក់ទងទៅនឹងការប្រើប្រាស់នៃទំនិញ។

(IX). គោលបំណងនៃវិធាននេះ ទំនិញល្បាយដែលធ្វើឡើងដោយសមាសភាគផ្សេងៗ មិនគ្រាន់តែមានសមាសភាគដែលភ្ជាប់មកជាមួយគ្នាមួយដើម្បីផ្តុំឱ្យបានជាទំនិញទាំងស្រុង នោះទេ ទោះជាដាច់គ្នាក៏ដោយ សមាសធាតុទាំងនេះ ទទួលស្គាល់ថាជាផ្នែកមួយ និងអាចប្រើបំពេញអោយគ្នាទៅវិញទៅមក ហើយផ្នែកទាំងអស់នោះត្រូវប្រើសំរាប់បង្កើតឱ្យបាននូវទំនិញទាំងស្រុងមួយ ដែលទំនិញនោះមិនអាចដាក់លក់ជាបំណែកៗបានដាច់ពីគ្នាបានឡើយ ។

ឧទាហរណ៍ទំនិញដូចខាងក្រោម :

(១). ចានកន្ទុយបារីដែលរួមមានជើងទម្រ ដែលអាចដោះយកចានចេញពីជើងទម្របាន ។

(២). ធ្វើដាក់ដាក់គ្រឿងទេសសំរាប់ប្រើក្នុងផ្ទះ ដែលមានគ្រោងរចនាបថជាពិសេស (ធម្មតាធ្វើពីឈើ) និងមានរូបរាង និងទំហំសមល្មមសំរាប់ក្រឡទទេសំរាប់ដាក់គ្រឿងទេស ។

ដូចនៅក្នុងវិធានខាងលើ សមាសភាគនៃទំនិញល្បាយនោះត្រូវតែដាក់ក្នុងកញ្ចប់រួមមួយ ។

(X). ចំពោះវិធាននេះ ពាក្យថា "ទំនិញរៀបចំសំរាប់លក់រាយ" មានន័យថា ទំនិញទាំងឡាយណាដែល :

ក. រួមមានយ៉ាងតិចវត្ថុធាតុពីរផ្សេងគ្នា ដែលអាចចាត់ថ្នាក់ក្នុងទីតាំងពីរផ្សេងគ្នា ។ ដូចនេះតាមខ្លឹមសារនៃវិធាននេះ ជាឧទាហរណ៍ សមសំរាប់ហូនខ្ចចំនួន ៦ មិនអាចចាត់ថាជាទំនិញជាសម្រាប់បានទេ។

ខ. រួមមានផលិតផល ឬវត្ថុធាតុដែលដាក់បញ្ចូលគ្នាបដើម្បីឆ្លើយតបនឹងតំរូវការជាក់លាក់ណាមួយ ឬអនុវត្តនូវសកម្មភាពជាក់លាក់ណាមួយ និង

គ. ដាក់បញ្ចូលគ្នា សមស្របសំរាប់លក់ជូនអ្នកប្រើប្រាស់ដោយផ្ទាល់ ដោយគ្មានការវេចខ្ចប់ឡើងវិញទេ (ដូចជាដាក់ក្នុងប្រអប់ ឡាំង ឬកិសជាដើម)។

ដូចនេះ ពាក្យនេះគ្របដណ្តប់ ជាឧទាហរណ៍ ចំពោះទំនិញមួយសម្រាប់ដែលរួមមានគ្រឿងអាហារផ្សេងៗសំរាប់ប្រើជាមួយនឹងគ្រឿងម្ហូបដែលគេចំអិនហើយ ។

ឧទាហរណ៍ សំរាប់ទំនិញមួយសម្រាប់ ដែលអាចចាត់ថ្នាក់បានដោយយោងទៅលើវិធានទី ៣ខ មានដូចតទៅ :

(១) ក. ទំនិញមួយសម្រាប់ រួមមានសាំងវិចសាច់គោ ទោះមានឬគ្មានប្រូម៉ាហ្ស ដាក់ក្នុងប្រអប់ នៃទីតាំងលេខ ១០.០២ វេចជាមួយចំណិតដំឡូងបារាំង (French fries) នៃទីតាំងលេខ ២០.០៤ :

ការចាត់ថ្នាក់ត្រូវនៅទីតាំងលេខ ១៦.០២ ។

ខ.ទំនិញមួយវត្ថុជាសម្រាប់ សមាសភាគរបស់វាត្រូវបានប្រើប្រាស់ជាមួយគ្នានៅក្នុងការរៀបចំអាហារស្ពាហ្គេទី រួមមានកញ្ចប់នៃស្ពាហ្គេទីមិនទាន់ចំអិន (ទីតាំងលេខ ១៩.០២) កញ្ចប់តូចៗនៃប្រូម៉ាហ្ស (ទីតាំងលេខ ០៤.០៦) និងកំប៉ុងតូចៗ នៃទឹកជ្រលក់ប៉េងប៉ោះ (ទីតាំងលេខ ២១.០៣) ដាក់នៅក្នុងប្រអប់កាតុង :

ការចាត់ថ្នាក់ ត្រូវនៅក្នុងទីតាំងលេខ ១៩.០២ ។

ទោះជាយ៉ាងណាក៏ដោយ វិធាននេះមិនគប់បញ្ចូលផលិតផលមួយចំនួន ដែលដាក់បញ្ចូលគ្នា ឧទាហរណ៍:

- ព្រានមួយកំប៉ុង(ទីតាំងលេខ ១៦.០៥) ប៉ាតេថ្លើមមួយកំប៉ុង Paté de foie (ទីតាំងលេខ ១៦.០២) ប្រូម៉ាហ្សមួយកំប៉ុង (ទីតាំងលេខ ០៤.០៦) សាច់បីជាន់ស្តើងៗមួយកំប៉ុង (ទីតាំងលេខ ១៦.០២) និងសាច់ក្រកកុតែមួយកំប៉ុង (ទីតាំងលេខ ១៦.០១)ឬ
- គ្រឿងស្រវឹងមួយដបទីតាំងលេខ ២២.០៨ និងស្រាមួយដបនៃទីតាំងលេខ ២២.០៤ ។

ករណីនៃឧទាហរណ៍ទាំងពីរខាងលើ និងផលិតផលប្រហាក់ប្រហែលគ្នាមួយចំនួន មុខទំនិញនីមួយៗ ត្រូវចាត់ថ្នាក់ដាច់ៗពីគ្នាទៅតាមទីតាំងសមស្របរបស់ខ្លួន ។

(២). គ្រឿងធ្វើសក់មួយសម្រាប់ រួមមានតុងទីអគ្គិសនីមួយ (ទីតាំងលេខ ៨៥.១០) ក្រាសសិតសក់មួយ (ទីតាំងលេខ ៩៦.០៣) កន្ត្រៃមួយ (ទីតាំងលេខ ៨២.១៣) ច្រាសមួយ (ទីតាំងលេខ ៩៦.០៣) និងកន្សែងពោះគោមួយ (ទីតាំងលេខ ៦៣.០២) ដាក់នៅក្នុងប្រអប់ស្បែកមួយ (ទីតាំងលេខ ៤២.០២) ។

ការចាត់ថ្នាក់ ត្រូវនៅក្នុងទីតាំងលេខ ៨៥.១០ ។

(៣). ឧបករណ៍សំរាប់គូរមួយប្រដាប់ មានបន្ទាត់មួយ (ទីតាំងលេខ ៩០.១៧), ម៉ាស៊ីនគណនាជាថាសមួយ (ទីតាំងលេខ ៩០.១៧), ដែកឈានមួយ (ទីតាំងលេខ ៩០.១៧), ខ្មៅដៃមួយ (ទីតាំងលេខ ៩៦.០៩) និងប្រដាប់ចិតខ្មៅដៃមួយ (ទីតាំងលេខ ៨២.១៤) ដាក់នៅក្នុងប្រអប់ផ្លាស្ទិកស្តើងមួយ (ទីតាំងលេខ ៤២.០២) ។

ការចាត់ថ្នាក់ ត្រូវនៅក្នុងទីតាំងលេខ ៩០.១៧ ។

ចំពោះវត្ថុជាសម្រាប់ដូចបានលើកឡើងខាងលើ ការចាត់ថ្នាក់ត្រូវបានធ្វើឡើងយោងទៅតាមសមាសភាគ ឬសមាសភាគផ្សំចូលគ្នា ដែលអាចត្រូវបានស្គាល់ថាសម្រាប់ទាំងមូលដែលមានលក្ខណៈសំខាន់ ។

(XI). វិធាននេះ មិនអាចអនុវត្តលើទំនិញដែលខ្ចប់ដាច់ៗពីគ្នាដាក់នៅជាមួយគ្នា ទោះជានៅ ឬមិននៅក្នុងកញ្ចប់តែមួយក៏ដោយ ឧទាហរណ៍ភេសជ្ជៈ (មានសមាមាត្រថេរមួយ នៃ ឧស្សាហកម្មផលិតភេសជ្ជៈ) ។

បំណកស្រាយវិធានទី ៣គ

(XII). នៅពេលដែលទំនិញមិនអាចចាត់ថ្នាក់បានតាមវិធានទី ៣ក ឬ ៣ខ ទំនិញទាំងនេះត្រូវចាត់ថ្នាក់នៅក្នុងទីតាំងមានលំដាប់លេខចុងក្រោយ ក្នុងចំណោមទំនិញដែលមានគុណសម្បត្តិស្មើគ្នាសំរាប់ការកំណត់ការចាត់ថ្នាក់នេះ ។

វិធានទី ៤

បណ្តាទំនិញដែលមិនអាចចាត់ថ្នាក់បានទៅតាមគោលការណ៍ខាងលើនេះ ត្រូវចាត់ថ្នាក់ទៅក្នុងទីតាំងពាក់ពន្ធ័នឹងវត្ថុដែលមានភាពប្រហាក់ប្រហែលបំផុត ។

បំណកស្រាយវិធានទី ៤

(I). វិធាននេះ ទាក់ទងទៅនឹងទំនិញដែលមិនធ្វើកាចាត់ថ្នាក់តាមវិធានទី ១ ដល់ ៣ ។ វិធាននេះ បញ្ជាក់ថាទំនិញបែបនោះត្រូវធ្វើកាចាត់ថ្នាក់ទៅទីតាំងសមស្របដែលជាទំនិញប្រហាក់ប្រហែលបំផុត ។

(II). នៅក្នុងកាចាត់ថ្នាក់ក្នុងវិធានទី៤ វាជាការចាំបាច់ដើម្បីប្រៀបធៀបទំនិញនេះមួយទៅនឹងទំនិញប្រហាក់ប្រហែល ដើម្បីធ្វើការកំណត់លេខសំគាល់ទំនិញនេះ ។ ទំនិញនេះត្រូវចាត់ថ្នាក់ទៅក្នុងទីតាំងដូចគ្នានឹងទំនិញប្រហាក់ប្រហែលបំផុត ។

(III). ជាការពិត ភាពប្រហាក់ប្រហែល គឺផ្អែកលើកត្តាជាច្រើន ដូចជាការបរិយាយលក្ខណៈ និងគោលបំណង ។

វិធានទី ៥

ក្រៅពីបទបញ្ញត្តិខាងលើនេះ វិធានតទៅនេះ ត្រូវតែអនុវត្តទៅលើទំនិញដែលចែកដូចខាងក្រោម :

ក- ស្រោមបិធានថតរូប ស្រោមសំរាប់ឧបករណ៍ភ្លេង កិសដាក់អាវុធ ហិបដាក់ប្រដាប់ប្រដាជាងគំនូរ ប្រអប់ (ដាក់មាសប្រាក់) និងប្រដាប់ប្រហាក់ប្រហែលពិសេសសំរាប់ដាក់វត្ថុនោះ កាលបើស្រោមប្រអប់ទាំងនោះ វាជាប្រភេទធម្មតាសំរាប់លក់ជាមួយឧបករណ៍ទាំង

នោះ ត្រូវបានចាត់ថ្នាក់ទៅតាមវត្ថុទាំងនោះ ។ ប៉ុន្តែ បទបញ្ញត្តិនេះ មិនអនុវត្តឡើយចំពោះស្រោមសំបកទាំងឡាយណាដែលសំរាប់ថែរក្សាលក្ខណៈសំខាន់នៃវត្ថុ ។

ខ- លើកលែងតែបទបញ្ញត្តិនៃវិធាន ៥ក ខាងលើនេះ សំបកវេចខ្ចប់ដែលក្នុងនោះមានដាក់ទំនិញត្រូវចាត់ថ្នាក់ជាមួយទំនិញទាំងនោះកាលបើវាសំរាប់ប្រើជាធម្មតាសំរាប់ទំនិញនោះ ។ ប៉ុន្តែបញ្ញត្តិនេះ មិនអនុវត្តទេកាលបើសំបកវេចខ្ចប់នោះដែលអាចយកទៅប្រើប្រាស់បានជាច្រើនដងទៅទៀត ។

ចំណារពន្យល់វិធានទី ៥ក

(កេស ប្រអប់ និង ស្រោមសំបកប្រហាក់ប្រហែល)

(I). វិធាននេះ គួររាប់បញ្ចូលតែសំបកទាំងឡាយណាដែល :

(១). ដែលត្រូវបានធ្វើជារាងពិសេស ឬតំឡើងសំរាប់ដាក់ឬផ្ទុកវត្ថុជាក់លាក់ណាមួយ ឬមួយសម្រាប់នៃវត្ថុ មានន័យថា ស្រោមសំបកវេចខ្ចប់ ត្រូវបានគេគ្រោងឡើងជាពិសេសឱ្យស្របទៅនឹងវត្ថុដែលគេមានបំណងដាក់ឬផ្ទុក ។ ស្រោមសំបកមួយចំនួនត្រូវបានគេធ្វើជារាងតាមទំរង់ដែលគេដែលគេចង់ដាក់ឬផ្ទុក ។

(២). សមស្របសំរាប់ការប្រើប្រាស់យូរអង្វែង មានន័យថា គេគ្រោងឡើងដើម្បីអោយមានរយៈពេលយូរអាចប្រៀបធៀបទៅនឹងវត្ថុដែលគេចង់ដាក់ឬផ្ទុកនោះ ។ សំបកទាំងនេះប្រើប្រាស់ផងដែរ សំរាប់ការការវត្ថុនៅពេលដែលមិនទាន់ប្រើប្រាស់(ឧទាហរណ៍ ក្នុងកំឡុងពេលដឹកជញ្ជូន ស្តុកទុក ឬរក្សាទុក)។ លក្ខណៈស្រោមសំបកទាំងនេះខុសពីលក្ខណៈនៃស្រោមសំបកធម្មតា ។

(៣). សំរាប់ដាក់ឬផ្ទុកវត្ថុ ទោះជាវត្ថុទាំងនោះ ត្រូវវេចខ្ចប់ដាច់ដោយឡែកពីសំបកដើម្បីងាយស្រួលដល់ការដឹកជញ្ជូនក៏ដោយ ។ ស្រោមសំបក ដែលនៅដាច់ដោយឡែកពីទំនិញ ត្រូវចាត់ថ្នាក់តាមទីតាំងសមស្របរបស់វា ។

(៤). គឺជាប្រភេទជាទូទៅលក់ជាមួយវត្ថុនោះ និង

(៥). មិនផ្តល់លក្ខណៈពិសេសរបស់វាទាំងមូល ។

(III). ឧទាហរណ៍ នៃស្រោមសំបក នាំមកជាមួយវត្ថុដែលត្រូវដាក់ឬផ្ទុក ត្រូវចាត់ថ្នាក់ដោយយោងតាមវិធាននេះ គឺ :

(១). ប្រអប់ និង ហិបគ្រឿងអលង្ការ (ទីតាំងលេខ ៧១.១៣)

(២). ប្រអប់ដាក់ប្រដាប់កោរពុកមាត់អគ្គិសនី (ទីតាំងលេខ ៨៥.១០)

(៣). ប្រអប់កែវយឺត ប្រអប់កែវពង្រីក (ទីតាំងលេខ ៩០.០៥)

(៤). ប្រអប់ដាក់ឧបករណ៍តន្ត្រី ប្រអប់ និងថង់ (ឧទា. ទីតាំងលេខ ៩០.០២)

(៥). កិលកាំភ្លើង (ឧទា. ទីតាំងលេខ ៩០.០៣)

(iii). ឧទាហរណ៍ នៃស្រោមសំបកមិនរាប់បញ្ចូលក្នុងវិធាននេះ គឺជាសំបកដូចជាកញ្ចប់តែមានដាក់តែ ឬធានសេរាមិកសំរាប់តុបតែងលំអមានស្ករគ្រាប់ក្នុងនោះ ។

បំណកស្រាយវិធានទី ៥ខ

(សំភារៈវេចខ្ចប់ និងសំបកវេចខ្ចប់)

(IV). វិធាននេះ គ្រប់គ្រងការចាត់ថ្នាក់នៃសំភារៈវេចខ្ចប់ និងសំបកវេចខ្ចប់ នៃប្រភេទមួយដែលជាទូទៅត្រូវបានប្រើប្រាស់សំរាប់វេចខ្ចប់ទំនិញដែលពាក់ព័ន្ធ ។ ទោះជាយ៉ាងណាក៏ដោយ បទបញ្ញាតិនេះ មិនចងនៅពេលដែលសំភារៈវេចខ្ចប់ឬសំបកវេចខ្ចប់បែបនេះ គឺបញ្ជាក់ច្បាស់ថាសមស្រប សំរាប់ការប្រើប្រាស់ដដែលៗ ឧទាហរណ៍ធុងដែក ឬ សំបកធ្វើពីដែកថែបឬដែកស្និតសំរាប់ដាក់ឧស្ម័ន ។

(V). វិធាននេះ គឺយោងតាមវិធានវិធីទី ៥ក ដូចនេះការចាត់ថ្នាក់កិលឬហិប ប្រអប់ និងស្រោមសំបកប្រហាក់ប្រហែល នៃប្រភេទដែលបានលើកឡើងនៅក្នុង វិធាន ៥ក ត្រូវកំណត់ ដោយការអនុវត្តន៍នៃវិធាននោះ ។

វិធានទី ៦

សំរាប់គោលបំណងស្របច្បាប់ ការចាត់ថ្នាក់ទំនិញចូលក្នុងទីតាំងរង នៃទីតាំងដូចគ្នា ត្រូវកំណត់ទៅតាមសព្ទ នៃទីតាំងរងទាំងនោះ និងតាមកំណត់សំគាល់ឬកំណត់សំគាល់ ដែលពាក់ព័ន្ធ និង (បើមានការចាំបាច់) ទៅតាមវិធានខាងលើ ហើយសូមបញ្ជាក់ថា អាចប្រៀបធៀបគ្នាបាន ចំពោះតែវត្ថុដែលស្ថិតនៅក្នុងទីតាំងរងដែលមានកំរិតដូចគ្នា ។ គោលបំណងនៃវិធាននេះ បណ្តាកំណត់សំគាល់នៃផ្នែកនីមួយៗ និងជំពូកនីមួយៗ ត្រូវអនុវត្តផងដែរ លើកលែងតែមានបទបញ្ញត្តិផ្ទុយគ្នា ។

បំណកស្រាយវិធានទី ៦

(I). វិធានទី ១ ដល់ ៥ (បើមានការចាំបាច់) ខាងលើសំរាប់អនុវត្តចំពោះការចាត់ថ្នាក់លើកំរិតទីតាំងរងជាមួយ និងទីតាំងនោះ ។

(II). គោលបំណងនៃវិធានទី៦ ឃ្លាប្រយោគខាងក្រោមមានន័យសំរាប់អ្វីដែលបានកំណត់ថា:

(ក). "ទីតាំងរងមានកំរិតដូច" មានន័យថា ទីតាំងរងដែលមានវង្កុសញ្ញាមួយ (កំរិត ១) ឬទីតាំងរងដែលមានវង្កុសញ្ញាពីរ (កំរិត ២) ។ ដូច្នេះ នៅពេលគិតទៅដល់គុណ

សម្បត្តិពាក់ពន្ធ័ដល់ទីតាំងវេងមានវេជ្ជសញ្ញាពីរ ឬច្រើននៅក្នុងទីតាំងតែមួយ ដែលបានបកស្រាយក្នុងវិធានទី ៣ក នោះ លក្ខណៈពិសេសរបស់វាពាក់ពន្ធ័ដល់វត្ថុណាមួយនោះ ត្រូវតែអាចធ្វើបានដោយឈរលើមូលដ្ឋាន នៃអត្ថបទ នៃទីតាំងដែលមានវេជ្ជសញ្ញាមួយណាមួយនោះ ។ នៅពេលដែលទីតាំងវេងមានវេជ្ជសញ្ញាមួយ ដែលមានភាពជាក់ច្បាស់បំផុតត្រូវបានជ្រើសយក ហើយនៅពេលទីតាំងវេងនោះ អាចបំបែកទីតាំងវេងបន្តទៅទៀតនោះ គេត្រូវតែគិតពិចារណាតែអត្ថបទ នៃទីតាំងវេងដែលមានវេជ្ជសញ្ញាពីរ ដើម្បីសំរេចយកទីតាំងវេងដែលមានវេជ្ជសញ្ញាពីរ ។

(ខ). ពាក្យថា "លើកលែងតែមានចែងនៅបរិបទដទៃ": គឺមានន័យលើកលែងតែកំណត់សំគាល់នៃផ្នែក ឬជំពូក មិនអាចយកមកប្រើបានចំពោះអត្ថបទ នៃទីតាំងវេង ឬកំណត់សំគាល់នៃទីតាំងវេង ។ ឧទាហរណ៍ នៅក្នុងជំពូកទី ៧១ នៅពេលដែលការដោះស្រាយចំពោះពាក្យ "PLATINUM" នៅក្នុងកំណត់សំគាល់ នៃជំពូកទី ៤ខ ខុសគ្នាពីពាក្យ "PLATINUM" នៅក្នុងកំនត់សំគាល់ទី ២ នៃទីតាំងវេង ។ ដើម្បីបកស្រាយទីតាំងវេងលេខ ៧១១០.១១ និង ៧១១០.១៩ គេត្រូវយកកំណត់សំគាល់ទីតាំងវេងលេខ ២ មកអនុវត្ត រីឯកំណត់សំគាល់ទី ៤ខ នៃ ជំពូកមិនត្រូវយកមកគិតឡើយ ។

(III). វិសាលភាពទីតាំងវេងដែលមានវេជ្ជសញ្ញាពីរ មិនត្រូវបានពង្រីកអោយហួសពីក្របខ័ណ្ឌនៃទីតាំងវេងដែលមានវេជ្ជសញ្ញាមួយ ដែលទីតាំងវេងមានវេជ្ជសញ្ញាពីរត្រូវតែស្ថិតនៅ និង វិសាលភាពនៃទីតាំងដែលមានវេជ្ជសញ្ញាមួយ មិនត្រូវពង្រីកអោយហួសពីក្របខណ្ឌ នៃទីតាំង ដែលទីតាំងវេងដែលមានវេជ្ជសញ្ញាមួយស្ថិតនៅ ។

2007

GENERAL RULES FOR THE INTERPRETATION OF THE HARMONIZED SYSTEM

CLASSIFICATION OF GOODS IN THE NOMENCLATURE SHALL BE GOVERNED BY THE FOLLOWING PRINCIPLES:

RULE 1

THE TITLES OF SECTIONS, CHAPTERS AND SUB-CHAPTERS ARE PROVIDED FOR EASE OF REFERENCE ONLY; FOR LEGAL PURPOSES, CLASSIFICATION SHALL BE DETERMINED ACCORDING TO THE TERMS OF THE HEADINGS AND ANY RELATIVE SECTION OR CHAPTER NOTES AND, PROVIDED SUCH HEADINGS OR NOTES DO NOT OTHERWISE REQUIRE, ACCORDING TO THE FOLLOWING PROVISIONS:

EXPLANATORY NOTE

(I) The nomenclature sets out in systematic form the goods handled in international trade. It grouped these goods in Sections, Chapters and sub-Chapters which have been given titles indicating as concisely as possible the categories or types of goods they cover. In many cases, however, the variety and numbers of goods classified in a Section or Chapter are such that it is impossible to cover them all or to cite them specifically in the titles.

(II) Rule 1 begins therefore by establishing that the titles are provided "for ease of reference only". They accordingly have no legal barring on classification.

(III) The second part of this Rule provides that classification shall be determined:
(a) according to the terms of the headings and any relative Section or Chapter Notes, and
(b) where appropriate, provided the headings or Notes do not otherwise require, according to the provisions of Rule 2,3, 4 and 5.

(IV) Provision (III) (a) is self-evident, and many goods are classified in the Nomenclature without recourse to any further consideration of the Interpretative Rules (e.g., live horses (heading 01.01), pharmaceutical goods specified in Note 4 to Chapter 30 (heading 30.06)).

(V) In provision (III) (b), the expression "provided such headings or Notes do not otherwise require" is intended to make it quite clear that the terms of the headings and any relative Section or Chapter Notes are paramount, i.e., they are the first consideration in determining classification. For example, in Chapter 31, the Notes provide that certain headings relate only to particular goods. Consequently those headings cannot be extended to include goods which otherwise might fall there by reason of the operation of Rule 2 (b).

RULE 2

(a). ANY REFERENCE IN A HEADING TO AN ARTICLE SHALL BE TAKEN TO INCLUDE A REFERENCE TO THAT ARTICLE INCOMPLETE OR UNFINISHED, PROVIDED THAT, AS PRESENTED, THE INCOMPLETE OR UNFINISHED ARTICLE HAS THE ESSENTIAL CHARACTER OF THE COMPLETE OR FINISHED ARTICLE. IT SHALL ALSO BE TAKEN TO INCLUDE A REFERENCE TO THAT ARTICLE COMPLETE OR FINISHED (OR FALLING TO BE CLASSIFIED AS COMPLETE OR FINISHED BY VIRTUE OF THIS RULE), PRESENTED UNASSEMBLED OR DISASSEMBLED.

(b). ANY REFERENCE IN A HEADING TO A MATERIAL OR SUBSTANCE SHALL BE TAKEN TO INCLUDE A REFERENCE TO MIXTURES OR COMBINATIONS OF THAT MATERIAL OR SUBSTANCE WITH OTHER MATERIALS OR SUBSTANCES. ANY REFERENCE TO GOODS OF A GIVEN MATERIAL OR SUBSTANCE SHALL BE TAKEN

TO INCLUDE A REFERENCE TO GOODS CONSISTING WHOLLY OR PARTLY OF SUCH MATERIAL OR SUBSTANCE. THE CLASSIFICATION OF GOODS CONSISTING OF MORE THAN ONE MATERIAL OR SUBSTANCE SHALL BE ACCORDING TO THE PRINCIPLES OF RULE 3.

EXPLANATORY NOTES

RULE 2 (a)

(Incomplete or unfinished articles)

(I) The first part of Rule 2 (a) extends the scope of any heading which refers to a particular article to cover not only the complete article but also that article incomplete or unfinished, provided that, as presented, it has the essential character of the complete or finish article.

(II) The provisions of this Rule also apply to blanks unless these are specified in a particular heading. The term "blank" means an article, not ready for direct use, having the approximate shape or outline of the unfinished article or part, and which can only be used, other than in exceptional cases, for completion into the finished article or part.

Semi-manufactures not yet having the essential shape of the finished articles (such as is generally the case with bars, discs, tubes, etc.) are not regarded as "blanks".

(III) In view of scope of the heading of Section I to IV, this part of the Rules does not normally apply to goods of these Sections.

(IV) Several cases covered by the Rule are cited in the General Explanatory Notes to Sections or Chapters (e.g., Section XVI, and Chapters 61, 62, 86, 87 and 90).

RULE 2 (a)

(Articles presented unassembled or disassembled)

(V) The second part of Rule 2 (a) provides that complete or finished articles presented unassembled or disassembled are to be classified in the same heading as the assemble article. When goods are so presented, it usually for reasons such as requirements or convenience of packing, handling or transport.

(VI) This Rule also applies to incomplete or unfinished articles presented unassembled or disassembled provided that they are to be treated as complete or finished articles by virtue of the first part of this Rule.

(VII) For the purposes of this Rule, "articles presented unassembled or disassembled" means articles the components of which are to be assembled either by means of simple fixing devices (screws, nuts, bolt, etc.,) OR by riveting or welding, for example, provided only simple assembly operation are involved. Unassembled components of an article, which are in excess of the number required for that article when compete, are to be classified separately.

(VIII) Cases covered by this Rule are cited in the General Explanatory Notes to Sections or Chapters (e.g., Section XVI, and Chapter 44, 86, 87 and 89).

(IX) In view of the scope of the headings of Section I to VI this part of the Rule does not normally apply to goods of these Sections,

RULE 2 (b)

(Mixtures and Combinations of materials or substances)

(X) Rule 2 (b) concerns mixtures and combinations of materials or substances, and goods consisting of two or more materials or substances. The Headings to which it refers are headings in which there is a reference to a material or substance (e.g., headings 05.03 - horsehair), and headings in

which there is a reference to goods of a given material or substance (e.g., heading 45.03 - article of natural cork). It will be noted that the Rule applies only if the headings or the Section or Chapter Notes do not otherwise require (e.g., heading 15.03 - lard oil, not ... mixed).

Mixtures being preparations described as such in a Section or Chapter Note or in a heading text are to be classified under the provision of Rule 1.

(XI) The effect of the Rule is to extend any heading to a material or substance to include mixtures or combination of that material or substance with other material or substances. The effect of the Rule is also to extend any heading referring to goods of a given material or substance to include goods consisting partly to that material or substance.

(XII) It does not, however, widen the heading so as to cover goods which cannot be regarded as required under Rule 1, as answering the description in the heading; this occurs where the addition of another material or substance deprives the goods of the character of goods of the kinds mentioned in the heading.

(XIII) As a consequence of this Rule, mixtures and combinations of materials or substances, and goods consisting of more than one materials or substance, if *prima facie* classifiable under two or more headings, must therefore be classified according to the principles of Rule 3.

RULE 3

WHEN BY APPLICATION OF RULE 2(b) OR FOR ANY OTHER REASON, GOODS ARE, *PRIMA FACIE*, CLASSIFIABLE UNDER TWO OR MORE HEADINGS, CLASSIFICATION SHALL BE EFFECTED AS FOLLOWS:

(A). THE HEADING WHICH PROVIDES THE MOST SPECIFIC DESCRIPTION SHALL BE PREFERRED TO HEADINGS PROVIDING A MORE GENERAL DESCRIPTION. HOWEVER, WHEN TWO OR MORE HEADINGS EACH REFER TO PART ONLY OF THE MATERIALS OR SUBSTANCES CONTAINED IN MIXED OR COMPOSITE GOODS OR TO PART ONLY OF THE ITEMS IN A SET PUT UP FOR RETAIL SALE, THOSE HEADINGS ARE TO BE REGARDED AS EQUALLY SPECIFIC IN RELATION TO THOSE GOODS, EVEN IF ONE OF THEM GIVES A MORE COMPLETE OR PRECISE DESCRIPTION OF THE GOODS.

(B). MIXTURES, COMPOSITE GOODS CONSISTING OF DIFFERENT MATERIALS OR MADE UP OF DIFFERENT COMPONENTS, AND GOODS PUT UP IN SETS FOR RETAIL SALE, WHICH CANNOT BE CLASSIFIED BY REFERENCE TO 3 (a), SHALL BE CLASSIFIED AS IF THEY CONSISTED OF THE MATERIAL OR COMPONENT WHICH GIVES THEM THEIR ESSENTIAL CHARACTER, INSOFAR AS THIS CRITERION IS APPLICABLE.

(C). WHEN GOODS CANNOT BE CLASSIFIED BY REFERENCE TO 3 (a) OR 3 (b), THEY SHALL BE CLASSIFIED UNDER THE HEADING WHICH OCCURS LAST IN NUMERICAL ORDER AMONG THOSE WHICH EQUALLY MERIT CONSIDERATION.

EXPLANATORY NOTE.

(I) This Rule provides three methods of classifying goods which, *prima facie* fall under two or more headings, either under the term of Rule 2(b) or for any other reasons. These methods operate in the order in which they are set out in the Rule. Thus Rule 3(b) operates only if Rule 3(a) fails in classification, and if both Rule 3(a) and (b) fail. Rule 3(c) will apply. The order of priority is therefore (a) specific description; (b) essential character; (c) heading which occurs last in numerical order.

(II) The Rule can only take effect provided the term of headings or Sections or Chapter notes do not otherwise require. For instance, note 4(b) to Chapter 97 requires that goods covered both by the description in one of the headings 97.01 to 97.05 and by the description in heading 97.06 shall be classified in one of the former heading. Such goods are to be classified according to note 4(b) to Chapter 97 and not according to this Rule.

Rule 3(a)

(III) The first method of classification is provided in Rule 3(a), under which the heading, which provides the most specific description of the goods, is to be preferred to a heading, which provides a more general description.

(IV) It is not practicable to lay down hard and fast rules by which to determine whether one heading more specifically describes the goods than another does, but in general it may be said that:

(a) A description by name is more specific than a description by class (e.g., Shavers and hair clippers, with self-contained electric motor, are classified in heading 85.10 and in heading 85.08 as electro-mechanical tools for working in the hand or in heading 85.09 as electro-mechanical domestic appliances with self-contained electric motor).

(b) If the goods answer to a description which more clearly identifies them, that this description is more specific than one where identification is less complete.

Examples of latter category of goods are:

(1) Tufted textile carpet, identifiable for use in motor cars, which are to be classified not as accessories of motor cars in heading 87.08 but in heading 57.03, where they are more specifically described as carpets.

(2) Unframed safety glass consisting of toughened or laminated glass, shaped and identifiable for use in aero planes, which is to be classified not in heading 88.03 as parts of goods in heading 88.01 or 88.02 but in heading 70.07, where it is more specifically described as safety glass.

(V) However, when two or more headings each refer two parts only of the materials or substances contained in mixed or composite goods or to part only of the items in a set put up for retail sale, those headings are to be regarded as equally specific in relation to those goods, even if one of them gives a more complete or precise description than the others. In such cases, Rule 3(b) or 3(c) shall determine the classification of goods.

Rule 3(b)

(VI) This second method relates only to:

(i) Mixtures.
(ii) Composite goods consisting of different materials.
(iii) Composite goods consisting of different components.
(iv) Goods put up in set for retail sales.
It applies only if Rule 3(a) fails.

(VII) In all these cases the goods are to be classified as if they consisted of the material or component which gives them their essential character, in so far as this criterion is applicable.

(VIII) The factor, which determines essential character, will vary as between different kinds of goods. It may, for example, be determined by the nature of the nature material or component, its bulk, quantity, weight or value, or by the role of a constituent material in relation to the use of the goods.

(IX) For the purposes of this Rule, composite goods made up of different components shall be taken to mean not only those in which the components are attached to each other to form a practically in separable whole but also those with separable components, provided these components are adapted one to the other and are mutually complementary and that together they form a whole which would not normally be offered for sale in separate parts.

Example of latter category of goods are:

(1) Ashtrays consisting of a stand incorporating a removable ash bowl.
(2) Household spice racks consisting of a specially design frame (usually of wood) and an appropriate number of empty spice jars of suitable shape and size.
As a general rule, the components of these composites goods are put up in common packing.

(X) For the purposes of this Rule the term "goods put up in sets for retail sale" shall be taken to mean goods which:

(a) Consist of at least two different articles, which are, *prima facie*, classifiable in different heading. Therefore, for example, six fondue fork cannot be regarded as a set within the meaning of this Rule;

(b) Consist of product or article put up together to meet a particular need or carry out a specific activity; and

(c) Are put up in a manner suitable for sale directly to users without repacking (e.g. in boxes or cases or on boards).

The term therefore covers sets consisting, for example, of different foodstuffs intended to be used together in the preparation of ready-to-eat dish or meal.

Examples of sets, which can be classified by reference to Rule 3(b), are:

(1) (a) Sets consisting of a sandwich made of beef, with or without cheese, in a bun heading 10.02, packaged with potatoes chips(French fries) (heading 20.04)

Classification in heading 16.02.

(b) Sets, the components of which are intended to be used together in the preparation of spaghetti meal, consisting of packed of uncooked spaghetti (heading 19.02) a sachet of grated cheese of heading 04.06 and a small tin of potatoes sauce heading 21.03), put up in a carton.

Classification in heading 19.02.

The rule does not, however, cover selections of products put up together and consisting for example of:

- A can of shrimps (heading 16.05), a can of ***pate de foil*** (heading 16.02), a can of cheese (heading 04.06), a can of sliced bacon (heading 16.02), and a can of cocktail sausages (heading 16.01); or
- A bottle of spirits of heading 22.08 and a bottle of wine of heading 22.04.

In the case of these two examples and similar selections of products, each item is to be classified separately in its own appropriate heading.

(2) Hairdressing sets consisting of a pair of electric hair clipper (heading 85.10), a comb (heading 96.15) a pair scissors (heading 82.13) a brush (heading 96.03) and a towel of textile material (heading 63.02), put up in a leather case (heading 42.02).

Classification of heading 85.10.

(3) Drawing kits comprising a ruler (heading 90.17), a disc calculator (heading 90.17), a drawing compass (heading 90.17), a pencil (heading 96.09) and a pencil sharpener (heading 82.14), put up in a case of plastic sheeting (heading 42.02)

Classification of heading 90.17.

For the sets mentioned above, the classification is made according to the component, or components taking together, which can be regarded as conferring on the set as a whole its essential character.

(XI) This Rule does not apply to goods consisting of separately packed constituents put up together, whether or not in common packing, in fixed proportions for the industrial manufacture of, for example, beverages.

Rule 3(c)

(XII) When goods cannot be classified by references to Rule 3(a) or 3(b), they are to be classified in the heading, which occurs last in numerical order among those which equally merit consideration in determining their classification.

RULE 4

GOODS WHICH CANNOT BE CLASSIFIED IN ACCORDANCE WITH THE ABOVE RULES SHALL BE CLASSIFIED UNDER THE HEADING APPROPRIATE TO THE GOODS TO WHICH THEY ARE MOST AKIN.

EXPLANATORY NOTE

(I) This Rule relates to goods which cannot be classified in accordance with Rule 1 to 3. It provides that such goods shall be classify under the heading appropriate to which they are most akin.

(II) In classifying in accordance with Rule 4, it is necessary to compare the presented goods with similar goods in order to determine the goods to which the presented goods are most akin.

(III) Kinship can, of course, depend on many factors, such as description, character, and purpose.

RULE 5

IN ADDITION TO THE FOREGOING PROVISIONS, THE FOLLOWING RULES SHALL APPLY IN RESPECT OF THE GOODS REFERRED TO THEREIN:

(a). CAMERA CASES, MUSICAL INSTRUMENT CASES, GUN CASES, DRAWING INSTRUMENT CASES, NECKLACE CASES AND SIMILAR CONTAINERS, SPECIALLY SHAPED OR FITTED TO CONTAIN A SPECIFIC ARTICLE OR SET OF ARTICLES, SUITABLE FOR LONG-TERM USE AND PRESENTED WITH THE ARTICLES FOR WHICH THEY ARE INTENDED, SHALL BE CLASSIFIED WITH SUCH ARTICLES WHEN OF A KIND NORMALLY SOLD THEREWITH. THIS RULE DOES NOT, HOWEVER, APPLY TO CONTAINERS WHICH GIVE THE WHOLE ITS ESSENTIAL CHARACTER;

(b). SUBJECT TO THE PROVISIONS OF RULE 5 (a) ABOVE, PACKING MATERIALS AND PACKING CONTAINERS PRESENTED WITH THE GOODS THEREIN SHALL BE CLASSIFIED WITH THE GOODS IF THEY ARE OF A KIND NORMALLY USED FOR PACKING SUCH GOODS. HOWEVER, THIS PROVISION IS NOT BINDING WHEN SUCH PACKING MATERIALS OR PACKING CONTAINERS ARE CLEARLY SUITABLE FOR REPETITIVE USE.

EXPLANATORY NOTE

Rules 5(a)

(Cases, boxes, and similar containers)

(I) This Rule shall be taken to cover only those container which

(1) Are specially shaped or fitted to contain a specific article or set of articles, i.e., they are designed specifically to accommodate the article for which they are intended. Some containers are shaped in tile form of the article they contain:

(2) Are suitable for long-term use. i.e., they are designed to have a durability comparable to that of the article for which they are intended. These containers also serve to protect the article

when not in use (during transport or storage, for example). These criteria enable them to be distinguished from simple packing;

(3) Are presented with the articles for which they are intended, whether or not the articles are packed separately for convenient of transport. Presented separately the containers are classified in their appropriate headings;

(4) Are of a kind normally sold with such articles; and

(5) Do not give the whole its essential character.

(II) Example of container, presented with the article for which they are intended, which are to be classified by reference to this Rule are:

(1) Jewelry boxes and cases (heading 71.13);

(2) Electric shaver cases (heading 85.10);

(3) Binocular cases, telescope cases (heading 90.05);

(4) Musical instrument cases, boxes and bags (e.g., heading 92.02);

(5) Gun cases (e.g., heading 93.03).

(III) Examples of containers not cover by this Rule are containers such as a silver caddy containing tea, or an ornamental ceramic bowl containing sweets.

Rules 5(b)

(Packing materials and packing containers)

